## សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

---- * ----

# សារណាបញ្ចប់ការសិក្សា

# សង្គម និង រដ្ឋ ៖ របបសន្តិសុខសង្គម នៅព្រះរាជាណាចក្រកម្ពុជា ( ប.ស.ស )

ស្រាវជ្រាវពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លឹម ជេស្តា**

សាស្ត្រាចារ្យណែនាំ

លោក៖ **ឡឿក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ ថ្នាក់ $L_4C_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមាននាម **លឹម ជេស្តា** សូមបង្ហាញនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- **លោកឪពុក** និង **អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ព្រមទាំងផ្តល់ឱកាសឱ្យកូនទទួលបានការសិក្សាអប់រំ រហូតដល់ចប់ថ្នាក់បរិញ្ញាបត្រ។ លោកទាំងពីរ គឺជាម្លប់ដ៏មិនចេះរីងស្ងួតសម្រាប់កូន ហើយកូនសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរដែលមានចំពោះកូន។
- លោកគ្រូសាស្ត្រាចារ្យ **ឡើក ពិដោរ** ដែលចំនាយពេលវេលាដ៏មានតម្លៃ ក្នុងការជួយណែនាំ ផ្តល់ជំនួយជាគំនិតដ៏ថ្លៃថ្លា ព្រមទាំងកែតម្រូវទាំងបែបបទនៃការសសេរ និងពាក្យពេជន៍រហូតដល់ការសសេរត្រូវបានបញ្ចប់ជាស្ថាពរ។
- ឯកឧត្តមសាកលវិទ្យាធិការ លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងសាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តក្នុងដំណើរការគ្រប់គ្រង បណ្តុះបណ្តាល និងរៀបចំកម្មវិធីសិក្សាបង្រៀនខ្ញុំបាទ និងនិស្សិតទាំងអស់ក្នុងសាកលវិទ្យាល័យ។
- លោកនាយករង និងលោកអនុប្រធានការិយាល័យអធិការកិច្ច និងនីតិកម្មនៃបេឡាជាតិរបបសន្តិសុខសង្គមដែលបានចំនាយពេលដ៏មានតម្លៃក្នុងការផ្តល់ព័ត៌មាន និងការផ្តល់ឯកសារដែលពាក់ព័ន្ធជាច្រើនធ្វើឱ្យខ្ញុំបាទ អាចសម្រេចបាននូវកិច្ចការស្រាវជ្រាវនេះបានយ៉ាងជោគជ័យ។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពជូនពរលោក-អ្នកស្រី ឱ្យជួបប្រទៈនូវសុខភាពល្អ សុភមង្គល សិរីសួស្តី និងជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន។

# អារម្ភកថា

ក្រោយពីបានចំនាយពេលជិត៤ឆ្នាំ ក្នុងការសិក្សាក្រេបជញ្ជក់យកនូវចំណេះដឹងព្រមទាំងជំនាញ **នីតិសាស្ត្រ** នៅសកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ធ្វើឱ្យរូបខ្ញុំបាទទទួលបាននូវចំណេះដឹងជាច្រើនតាមមុខវិជ្ជាផ្សេងៗដូចជាៈ នីតិវិធីព្រហ្មទណ្ឌ នីតិវិធីរដ្ឋប្បវេណី នីតិពាណិជ្ជកម្ម នីតិរដ្ឋធម្មនុញ្ញ និងនីតិការងារជាដើម។ ហេតុដូចនេះ ហើយដើម្បីឆ្លើយតបនឹងការបញ្ចប់ការសិក្សារបស់ខ្ញុំបាទ ជាចុងក្រោយខ្ញុំបានសំរេចចិត្តជ្រើសរើសនូវប្រធានបទមួយឡើងស្តីពី" **សន្តិសុខសង្គម និង រដ្ឋ: របបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា**(ប.ស.ស)" ។

ខ្ញុំបាទបានធ្វើការបកស្រាយយ៉ាងល្អិតល្អន់ និងច្បាស់លាស់ពីរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជាដែលស្ថាប័នមួយជាអ្នកទទួលបន្ទុកផ្ទាល់មានឈ្មោះថាបេឡាជាតិរបបសន្តិសុខសង្គមដែលទទួលរាប់រងនូវរបបហានិភ័យការងារ និងរបបថែទាំសុខភាពជូនចំពោះកម្មករនិយោជិតដែលកំពុងបំរើការងារក្នុងសហគ្រាស គ្រឹះស្ថាន នឹងទទួលបានផលប្រយោជន៍ពីរបបសន្តិសុខសង្គម។ ជាក់ស្តែងណាស់ និយោជក(ម្ចាស់សហគ្រាស) ក៏ទទួលបាននូវផលចំនេញ មិនត្រឹមតែការគិតគូរពីគ្រោះថ្នាក់ការងារ ប៉ុន្តែថែមទាំងការគិតគូរពីសុខភាពរបស់កម្មករនិយោជិត ជាផលប្រយោជន៍បានមកពី**របបសន្តិសុខសង្គម** ដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

ដូច្នេះ ខ្ញុំបាទសង្ឃឹមថាយ៉ាងមុតមាំថា ស្នាដៃនេះអាចជាឯកសារសម្រាប់មិត្តនិស្សិតដែលសិក្សាគ្រប់ជំនាន់ ព្រមទាំងអាចជាឯកសារបន្ថែមដល់សមាជិកបេឡាជាតិរបបសន្តិសុខសង្គមឱ្យដឹងពីផលប្រយោជន៍ដែលខ្លួនទទួលបាន។ ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធពរជ័យដល់មិត្តអ្នកអានទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ ព្រមទាំងសំដែងនូវការសប្បាយរីករាយជានិច្ច ចំពោះការរិះគន់ក្នុងន័យស្ថាបនាលើសៀវភៅនេះដើម្បីជាទុននូវចំណេះដឹងបន្ថែមសម្រាប់ខ្ញុំបាទតទៅមុខទៀត,សូមអរគុណ។

# **មាតិកា**

**ទំព័រ**

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១ប្រវត្តិសន្តិសុខសង្គម** ........ **២**

**ផ្នែកទី១ របបសន្តិសុខសង្គម** ........ **២**

**កថាខណ្ឌទី ១ ប្រវត្តិសន្តិសុខសង្គម** ........ **២**

**កថាខណ្ឌទី២ ប្រវត្តិ និងការបង្កើតរបបសន្តិសុខសង្គម នៅព្រះរាជាណាចក្រកម្ពុជា** ........ **២**

**ផ្នែកទី២ បេឡាជាតិរបបសន្តិសុខសង្គម** ........ **៥**

**កថាខណ្ឌទី១ ៖ ស្ថានភាពទូទៅ** ........ **៥**

ក/ លក្ខណៈទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម ........ **៥**

ខ/ រចនាសម្ព័ន ប.ស.ស ........ **៥**

គ/ តួនាទីបេឡាជាតិរបបសន្តិសុខសង្គម ........ **៦**

ឃ/ ប្រភពធនធាន ........ **៦**

ង/ ការចំណាយ ........ **៧**

**កថាខណ្ឌទី២ ៖ របបធានារ៉ាប់រងរបស់ប.ស.ស** ........ **៧**

ក/ ការដាក់ឲ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ........ **៧**

ខ. ដំណើរការរបបធានារ៉ាប់រងសុខភាព ........ **៨**

គ. ការពង្រីក និង អនុវត្តរបបប្រាក់សោធន ........ **៩**

**ជំពូកទី២ ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ** ........ **១០**

**ផ្នែកទី១ របបធានារ៉ាប់រងហានិភ័យការងារ** ........ **១០**

**កថាខណ្ឌទី១ ដំណាក់កាលនៃការទទួលបាន របបធានារ៉ាប់រងហានិភ័យការងារ** ........ **១០**

ក/ បញ្ជិកាសហគ្រាស និងគ្រឹះស្ថាន ........ **១០**

ខ/ បញ្ជីកម្មករនិយោជិត ........ **១០**

គ/ របាយការណ៍កម្មករនិយោជិត ........ **១០**

**កថាខណ្ឌទី២៖ ការកំណត់ភាគទានហានិភ័យការងារ** .................................... **១១**

ក/ ការបង់ភាគទាន .................................... **១១**

ខ/ អត្រាភាគទានហានិភ័យការងារ .................................... **១១**

គ/ ការបរិច្ឆេទនៃការបង់ភាគទាន .................................... **១២**

ឃ/ បែបបទ និង នីតិវិធីនៃការបង់ភាគទាន .................................... **១៣**

**ផ្នែកទី២ ហានិភ័យការងារ និង តាវកាលិក** .................................... **១៤**

**កថាខណ្ឌទី១ និយមន័យហានិភ័យការងារ** .................................... **១៤**

ក/ សញ្ញាណហានិភ័យការងារ .................................... **១៤**

ខ/ ការជូនដំណឹងហានិភ័យការងារ .................................... **១៤**

គ/ ការផ្តល់សេវាសង្គ្រោះបន្ទាន់ .................................... **១៥**

ឃ/ ការអង្កេតហានិភ័យការងារ .................................... **១៦**

ង/ ការផ្តល់សេវាថែទាំ និងព្យាបាល .................................... **១៦**

ច/ មន្ទីរពេទ្យដែលទទួលស្គាល់ដោយ
បេឡាជាតិរបបសន្តិសុខសង្គម .................................... **១៦**

**កថាខណ្ឌទី ២ ការទទួលបានតាវកាលិកហានិភ័យការងារ** .................................... **១៨**

ក/ ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់
សមត្ថភាពការងារបណ្តោះអាសន្ន .................................... **១៨**

ខ/ ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់
សមត្ថភាពការងារអចិន្ត្រៃយ៍ .................................... **២១**

គ/ ការទទួលបានតាវកាលិកចំពោះសមាជិកជនរងគ្រោះ .................................... **២៣**

ឃ/ សេវាបុននីតិសម្បទា .................................... **២៤**

ង/ ការទាមទារតាវកាលិក .................................... **២៥**

ច/ ការដោះស្រាយវិវាទ .................................... **២៦**

**ជំពូកទី៣ របបធានារ៉ាប់រងថែទាំសុខភាព** .................................... **២៧**

**ផ្នែកទី១ សេវាថែទាំសុខភាព** .................................... **២៧**

**កថាខណ្ឌទី១ ៖ ការអនុវត្តរបបធានារ៉ាប់រងសុខភាព** .................................... **២៧**

**កថាខណ្ឌទី២ ៖ នីតិវិធី និង បែបបទនៃការចុះ**
**បញ្ជិកាជាសមាជិក ប.ស.ស** ........ **២៧**
ក/ ចំពោះកម្មករនិយោជិត ........ **២៧**
ខ/ ចំពោះសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជិកានៅប.ស.ស ........ **២៨**
គ/ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី ........ **២៩**
ឃ/ សហគ្រាសដែលបានចុះបញ្ជីជាមួយប.ស.ស ........ **២៩**
**ផ្នែកទី២ មន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស** ........ **៣០**
**កថាខណ្ឌទី១ មូលដ្ឋានសុខាភិបាលជាដៃគូ** ........ **៣០**
ក/ កម្រិតនៃការផ្តល់សេវាសុខភាព ........ **៣១**
ខ/ តារាងស្ថិតិមន្ទីរពេទ្យ មន្ទីរពេទ្យបង្អែក និង
មណ្ឌលសុខភាពនៅរាជធានី/ខេត្ត ........ **៣២**
គ/ ប្រភពផ្តល់ និងទទួលព័ត៌មានរបស់ប.ស.ស ........ **៣៣**
ឃ/ ភ្នាក់ងារប.ស.ស ប្រចាំតាមបណ្តាមូលដ្ឋានសុខាភិបាល ........ **៣៤**
ង/ គណៈកម្មការវេជ្ជសាស្ត្រ ........ **៣៥**
**កថាខណ្ឌទី២ ៖ បែបបទនៃការបង់ភាគទាន និង តាវកាលិក** ........ **៣៥**
ក/ ការបង់ភាគទាន ........ **៣៥**
ខ/ អត្រាភាគទាន ........ **៣៦**
គ/ ការផ្តល់សេវាថែទាំសុខភាព ........ **៣៦**
ឃ/ តាវកាលិកថែទាំសុខភាព ........ **៤០**
ង/ ការទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រ ........ **៤១**
ច/ វិធីសាស្ត្រទូទាត់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ
ផ្នែកធានារ៉ាប់រងសុខភាព ........ **៤២**
**សេចក្តីសន្និដ្ឋាន** ........ **៤៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បច្ចុប្បន្ន ស្ថានភាពរបស់ប្រទេសកម្ពុជាមានការរីកចំរើនលើគ្រប់វិស័យក្នុងនោះមានវិស័យទាក់ទងនឹងវិស័យសន្តិសុខសង្គម។ ប្រជាជនកម្ពុជាបាននឹងទទួលផលពីរបបនេះ ជាពីសេស កម្មករនិយោជិតដែលបម្រើការងារនៅក្នុងសហគ្រាស គ្រឹះស្ថានផ្សេងៗ។ រដ្ឋ ជានិយ័តករដ៏សំខាន់ ក្នុងរឿងនេះដើម្បីការធានាសាមគ្គីសង្គម ការធានានូវប្រាក់ចំនូល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** និងសេនាធិការរួមមាន: ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវ: និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សន្តិសុខសង្គម មានលក្ខណ:ផ្សេងៗពីគ្នារវាងបណ្តាលប្រទេសនៅជុំវិញពិភពលោក។ ប៉ុន្តែនៅក្នុងន័យនេះបានបង្កប់នៅអត្តន័យមួយគឺជាវិធាននៃការជួយសម្រាកបន្ទុករស់នៅក្នុងគ្រួសារណាម្នាក់នៅក្នុងសង្គមដែលទទួលរងនៅការបាត់បង់ និងការធ្លាក់ចុះនូវប្រាក់ចំណូលជាដើមដែលពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសារបាន។ អនុលោមតាមន័យខាងលើ យើងអាចកំណត់បាននូវគោលបំណងបីធំៗនៃសន្តិសុខសង្គមគឺ៖

-ទី១ ការធានាចំពោះតម្រូវការចាំបាច់ក្នុងការថែទាំសុខភាព

-ទី២ ការធានាចំពោះតម្រូវការចាំបាច់ នៅពេលបាត់បង់ប្រាក់ចំណូលដោយសារហានិភ័យការងារ

-ទី៣ ការធានាចំពោះតម្រូវការចាំបាច់នៅពេលបន្ទុកគ្រួសារកើនឡើង។

សរុបសេចក្តីមកសន្តិសុខសង្គម គឺជាវិធានការគតិយុត្តចាំបាច់នានាដែលរដ្ឋ ឬរដ្ឋាភិបាលត្រូវចាត់ទុក្ខដើម្បីការពារចំពោះពលរដ្ឋរបស់ខ្លួនណាដែលមិនមានលទ្ធភាពរកបានប្រាក់ចំណូល ឬប្រឈមនឹងការទទួលខុសត្រូវខាងហិរញ្ញវត្ថុដោយបណ្តោះអាសន្ន ឬដោយអចិន្ត្រៃយ៍ក្តី ដោយសារហានិភ័យសង្គម ដើម្បីឱ្យពួកគេមានលទ្ធភាពដោះស្រាយជីវភាពរស់នៅចាំបាច់ បានតាមរយៈការផ្តល់នូវធនធានខាងហិរញ្ញវត្ថុ ឬវត្ថុប្រើប្រាស់ចាំបាច់ ឬការផ្តល់សេវាផ្សេងៗជាដើម។ រដ្ឋបាល សន្តិសុខសង្គមគឺជាអង្គការនៃនីតិឯកជនទទួលបេសកម្មនៃសេវាសាធារណ: ឬសេវាឯកជនដែលសេវានេះបម្រើឱ្យសេវាសាធារណ:ស្របច្បាប់។

សារណានេះផ្តោតជាសំខាន់ទៅលើការអនុវត្តជាក់ស្តែងពីរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជាដោយពេលខ្លះក្នុងបរិបទអន្តរជាតិ។

ដូច្នេះ ការគ្រប់គ្រងរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងខ្លឹមសារសំខាន់មានអ្វីខ្លះ?

ដើម្បីយល់ឱ្យកាន់តែច្បាស់ពី ការគ្រប់គ្រង និងការអនុវត្តនេះនៅព្រះរាជាណាចក្រកម្ពុជា ជាបឋមប្រវត្តិនៃរបបសន្តិសុខសង្គម នឹងត្រូវបានលើមកនិយាយមុនគេ(ជំពូកទី១) បន្ទាប់មកទៀត ការអនុវត្តជាក់ស្តែងក្នុងរបបនេះ(ជំពូកទី២ និងជំពូកទី៣)

# ជំពូកទី១
# ប្រវត្តិសន្តិសុខសង្គម
## ផ្នែកទី១ របបសន្តិសុខសង្គម

### កថាខណ្ឌទី១ ប្រវត្តិសន្តិសុខសង្គម

សន្តិសុខសង្គមបានចាប់ផ្តើមនៅក្នុងប្រទេសអាល្លឺម៉ង់មុនដំបូងគេ តាំងពីសតវត្សទី១៩ គឺក្នុងអំឡុងឆ្នាំ១៨៨១ ដោយព្រះរាជាឈ្មោះ កៃសឺ វាលលៀម (Kaiser Wilhelm) បានអនុវត្តប្រពន្ធ័ធានារ៉ាប់រងសង្គម សម្រាប់ប្រជាជនដែលធ្វើការនៅប្រទេសអាល្លឺម៉ង់ដែលជាគំនិតផ្តួចផ្តើមឡើងដោយអធិការបតីអាល្លឺម៉ង់ឈ្មោះ អូតតូវុន ប៊ីសម៉ាក(Otto von Bismarck)។ ប៉ុន្តែពាក្យថា *"សន្តិ សុខសង្គម"* ត្រូវបានគេប្រើដំបូងគេនៅក្នុងសហរដ្ឋអាមេរិកនៅក្នុងច្បាប់សន្តិសុខសង្គម(Social Security Act) ដែលអនុម័តនាថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៣៥ នៅក្នុងក្រមខណ្ឌកំណែទម្រង់សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ ប្រធានាធិបតី ហ្វ្រង់គ្លីនរ៉ូសឺវែល (President Franklin D. Roosevelt)។[9] ក្រោយមកពាក្យនេះ ត្រូវបានអង្គការសហប្រជាជាតិយកទៅប្រើប្រាស់ក្នុងសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធមនុស្សក្នុងឆ្នាំ១៩៤៨ ដែលចែងថា"មនុស្សគ្រប់រូបក្នុងឋានៈខ្លួនជាសមាជិកសង្គម ត្រូវមានសិទ្ធខាងសន្តិសុខសង្គម"។ បន្ទាប់ពាក្យសន្តិសុខសង្គម ត្រូវបានគេយកមកប្រើនៅក្នុងបណ្តាលប្រទេសជុំវិញពិភពលោក ជាពិសេសគឺ ប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៍សម្រាប់ជាវិធាន ដោះស្រាយ នូវទុក្ខលំបាករបស់ប្រជាជនដែលជួបនូវការខ្វះខាតនិងមិនអាចទ្រទ្រង់នូវជីវភាពខ្លួន និង ក្រុមគ្រួសារបាន ។

### កថាខណ្ឌទី២ ប្រវត្តិ និងការបង្កើតរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា

ក្រោយពីបានទទួលឯករាជ្យឆ្នាំ១៩៥៣ កម្ពុជាបានចេញព្រះរាជក្រមលេខ ៣ នស ចុះថ្ងៃ ទី២៥ ខែមេសា ឆ្នាំ១៩៥៥ ពាក់ពន្ធ័ដល់សិទ្ធកម្មករនិយោជិតក្នុងការទទួល បានប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ និងកូនដែលអាចចាត់ទុកជាការចាប់ផ្តើមឡើងនៃប្រពន្ធ័សន្តិសុខសង្គមនៅកម្ពុជា។ សន្តិសុខសង្គម ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ យោងតាមព្រះរាជក្រឹត្យលេខ៥៥ និង៣០៦។ តែគួរឲ្យសោកស្តាយ កំឡុងពេលរបបប្រល័យពូជសាសន៍(១៩៧៥-១៩៧៩)សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ ពីឆ្នាំ១៩៧៩-១៩៩៣ ប្រជាជនបានទទួលសេវាថៃទាំ

---
[9] ដក់ស្រង់ចេញពីគេហទំព័រ https://www.ssa.gov/history/age65.html

សុខភាពដោយឥតគិតថ្លៃ។ បន្ទាប់ពី ការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គម ត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះ ទទួលខុសត្រូវលើការរៀបចំទាំងអស់សម្រាប់ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជនដែលធ្វើការក្នុងវិស័យឯកជន[២]។

ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធទទួលបានការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមដែលមានចែងក្នុងច្បាប់"។[៣]ដូចដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសជាតិ និងជាបទបញ្ញត្តិសម្រាប់គាំពារសង្គមចំពោះប្រជាពលរដ្ឋទូទៅដោយមិនរើសអើងគ្រប់ទម្រង់ទាំងអស់ដែលរួមបញ្ចូលនូវសិទ្ធទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍សង្គមផ្សេងទៀត។ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដដែលក៏បានចែងអំពី "រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម"។[៤]

បទប្បញ្ញត្តិស្តីពីច្បាប់ការងារដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ(បច្ចុប្បន្នប្តូរទៅជាអគ្គនាយកដ្ឋានការងារ)។ ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនងវិជ្ជាជីវៈដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតដើម្បីធានាឱ្យមានលក្ខខណ្ឌល្អប្រសើររក្សាភាពសុខដុមរមនាក្នុងវិជ្ជាជីវៈពង្រឹងសុវត្ថិភាពការងារនិងនៅកន្លែងធ្វើការ។ បន្ទាប់ពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ជាមូលដ្ឋានគ្រឹះនៃការបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវបានអនុម័តដោយសភា នៅខែកញ្ញា ឆ្នាំ២០០២ ដែលគោលបំណងក្នុងច្បាប់នេះបង្កើតឱ្យមាន៖

១. ប្រាក់សោធនទទួលបន្ទុកផ្តល់តាវកាលិកជរាភាព ទុព្វលភាព និងមរណភាព។

២. ផ្នែកហានិភ័យការងារទទួលបន្ទុកផ្តល់តាវកាលិកគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។

ចំពោះផ្នែកផ្សេងទៀតត្រូវកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់ប្រទេសជាតិ ។

អនុក្រឹត្យលេខ១៦អនក្រ/បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានអនុម័តនៅឆ្នាំ២០០៧ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ បេឡាជាតិរបបសន្តិសុខសង្គមហៅកាត់ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារសន្តិសុខសង្គមឱ្យស្រប

---

[២] ដកស្រង់ចេញពីគេហទំព័រ ប.ស.ស http://www.nssf.gov.kh

[៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជំពូកទី៣ មាត្រា ៣៦ វាក្យខណ្ឌទី៤

[៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជំពូកទី៦ មាត្រា៧៥

ទៅតាមច្បាប់សន្តិសុខសង្គមជាតិ និងបទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាមអនុក្រឹត្យ ហើយបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០០៨ ។

## ផ្នែកទី២ បេឡាជាតិរបបសន្តិសុខសង្គម

### កថាខណ្ឌទី១ ស្ថានភាពទូទៅ

#### ក/ លក្ខណៈទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម

គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកម្មបម្រើសេវាផ្នែកសាធារណៈ មានលក្ខណៈសង្គមមានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "ប.ស.ស"។ ប.ស.ស ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[៥]

#### ខ/ រចនាសម្ព័ន ប.ស.ស

ប.ស.ស ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យ និងក្នុងក្របខណ្ឌបទបញ្ជាផ្ទៃក្នុងរបស់ប.ស.ស។ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចតទៅ៖ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(ប្រធាន) , តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១(មួយ)រូប, តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១(មួយ)រូប, តំណាងក្រសួងសុខាភិបាល ១(មួយ)រូប,តំណាងនិយោជក ២(ពីរ)រូប, តំណាងកម្មករនិយោជិតនៃប.ស.ស ២(ពីរ)រូប, និងនាយកនៃប.ស.ស ជាសមាជិកស្វ័យប្រវត្តិ។[៦]

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មការងារ ធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមតស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាពក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

តំណាងនិយោជក និងកម្មករនិយោជិតត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះ ត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាពក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទបមជ្ឈិម ឬឧក្រិដ្ឋ។

---

[៥] មាត្រា១ នៃអនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[៦] មាត្រា៤ នៃអនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃប.ស.ស ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំរៀបចំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈដែលសមាជិកនោះតំណាងឱ្យ។អាណត្តិនេះអាចបញ្ចប់ ឬអាចបន្តទៀតបានតាមសំណើរបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលសមាជិកនោះតំណាងឱ្យ។

### គ/ តួនាទីបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គមមានភារកិច្ចដូចជា[៧] ៖ គ្រប់គ្រងរបបសន្តិសុខសង្គមដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ,ធានាឱ្យមានការសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃប.ស.សក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ មាតុភាពជាដើម , ប្រមូលភាគទាន ពីសមាជិកនៃប.ស.ស និងនិយោជក, សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាលនិងសង្គមកិច្ចសម្រាប់ប្រយោជន៍ដល់សមាជិករបស់ខ្លួន, សហការជាមួយអង្គការ ពាក់ពន្ធ័ដើម្បីអប់រំផ្សព្វផ្សាយបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈការចាត់វិធានផ្នែកបច្ចេកទេសសន្តិសុខនិងអនាម័យការងារ , សហការជាមួយអង្គភាពពាក់ពន្ធ័ដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ , ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

### ឃ/ ប្រភពធនធាន

ប្រភពធនធាននៃ ប.ស.ស បានមកពី៖[៨] ធនធានដំបូងដែលរដ្ឋបានផ្តល់សម្រាប់ការបង្កើត ប.ស.ស, ការផ្ទេរជាលក្ខណៈអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការរដ្ឋដូចជា ឧបត្ថមធនសម្រាប់ដំណើរការ និងឧបត្ថមធនធានជាមូលធន , វិភាគទានរបស់សមាជិក និងនិយោជកដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម, ប្រាក់ពិន័យលើការយឺតយ៉ាវលើការបង់វិភាគទាន ឬផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនោះ , ផលចំនេញដែលបានមកពីការវិនិយោគ , អំណោយ និងអច្ច័យទានផ្សេងៗ, ប្រភពធនធានដទៃទៀតដែល ប.ស.ស អាចទទួលបានស្របតាមច្បាប់ ។

[៧] មាត្រា៣ នៃអនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
[៨] មាត្រា២០ នៃអនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

ង/ ការចំណាយ

ការចំណាយរបស់ ប.ស.ស រួមមាន៖[៩] ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ, ការចំណាយសម្រាប់ការងាររដ្ឋបាលនៃប.ស.ស , ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច , ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ ប.ស.ស ។

**កថាខណ្ឌទី២ របបធានារ៉ាប់រងរបស់ប.ស.ស**

ក/ ការដាក់ឱ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

បេឡាជាតិរបបសន្តិសុខសង្គមចាប់ផ្តើមជំហានទី១ គឺធានារ៉ាប់រងគ្រោះថ្នាក់ការងារ នាខែវិច្ឆិកា ឆ្នាំ២០០៨។ ដំណាក់កាលនៃការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវកំណត់ដូចជា៖[១០] របបធានារ៉ាប់រងហានិភ័យការងារចាប់ផ្តើមអនុវត្តនាឆ្នាំ២០០៨, ចំពោះរបបធានារ៉ាប់រងសុខភាពផ្នែកសោធន និងផ្នែកសន្តិសុខសង្គមដទៃទៀតនឹងត្រូវកំណត់ជាបន្តបន្ទាប់នៅពេលក្រោយ ។

ដំណាក់កាលចាប់ផ្តើមដំបូងផ្នែកធានារ៉ាប់រងហានិភ័យការងារ ត្រូវអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារដែលការធានារ៉ាប់រង ជាកតព្វកិច្ចគ្រប់ដណ្តប់លើកម្មករនិយោជិតទាំងអស់ដែលកំណត់ដោយច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីច្បាប់ការងារ។ របបធានារ៉ាប់រងគ្រោះថ្នាក់ការងារគ្រប់ដណ្តប់លើគ្រោះថ្នាក់ការងារ៖[១១]

ជនដែលត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គម តាមច្បាប់នេះ ដោយមិនមានបែងចែកពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនាគំនិតនយោបាយ ជាតិកំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជិព កម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជិពគឺ៖[១២] កម្មករនិយោជិត ទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រសិនបើជនទាំងនោះធ្វើសម្មភាពការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីជាប្រយោជន៍សម្រាប់និយោជកម្នាក់ ឬច្រើននាក់ដោយ

---

[៩] មាត្រា២១ នៃអនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[១០] ប្រការ១ នៃប្រកាសលេខ ០២២/០៨ កប.ប្រក ចុះថ្ងៃទី១១ ខែកម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃ ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

[១១] មាត្រា២៤៨ នៃច្បាប់ស្តីពីការងារ លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ១៩៩៧

[១២] មាត្រា៤ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២

មិនគិតពីភេទ ទម្រង់ និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទនៃចំនួននៃប្រាក់ឈ្នួលដែល ជននោះបានធ្វើឬបានទទួលឡើយ, កម្មករនិយោជិតរដ្ឋកម្មករនិយោជិតនៃអង្គការសាធារណៈ និងបុគ្គលិកទាំងអស់ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈទូតព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈដែលតែងតាំងដោយបណ្តោះអាសន្ន,សិស្សសាលាវិជ្ជាជីវៈជនដែលដាក់ឱ្យធ្វើការនៅក្នុងមណ្ឌលបណ្តុះបណ្តាលសម្របសម្រួល និងអប់រំវិជ្ជាជីវៈសារឡើងវិញ និងកូនជាងត្រូវចាត់ទុកដូចជាកម្មករនិយោជិត, ជនដែលប្រកបមុខរបរក្នុងវិជ្ជាជីវៈសេរីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម, កម្មករ និយោជិតធ្វើការម្តងម្កាល ឬតាមរដូវ។

នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូងផ្នែកធានារ៉ាប់រងហានិភ័យការងារ ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី០៨(ប្រាំបី)នាក់ឡើងទៅ។ ចំពោះសហគ្រាសគ្រឹះស្ថានផ្សេងពីនេះ ត្រូវនៅបន្តអនុវត្តតាមបទប្បបញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានការកំណត់ជាថ្មី។[១៣] របបធានារ៉ាប់រងហានិភ័យការងារត្រូវបានពង្រីកវិសាលភាពគ្រប់ដណ្តប់ ២៥ រាជធានី/ខេត្តនៅទូទាំងប្រទេស បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានចំនួន៦,១០៧ មានកម្មករនិយោជិត ៨៥២,២៤០ នាក់ និងបានផ្តល់តាវកាលិកគ្រោះថ្នាក់ការងារដល់សមាជិកចំនួនជាង៥(ប្រាំ)ម៉ឺននាក់ រហូតមកដល់ដំណាច់ឆ្នាំ២០១៣។[១៤]

របបហានិភ័យការងារនេះ ក៏បានដាក់ឱ្យប្រើប្រាស់ផងដែរ នៅប្រពន្ធ័ទូរសព្ទទំនាក់ទំនងបន្ទាន់(HotLine) ១២៨៦ និងចុះកិច្ចសន្យាជាមួយមន្ទីពេទ្យ និងមន្ទីសម្រាកព្យាបាលឯកជនបានចំនួន ៦៥ ដើម្បីឱ្យកម្មករនិយោជិតដែលរងគ្រោះថ្នាក់ការងារ ទទួលបាននូវការសង្គ្រោះបន្ទាន់ និងសេវាព្យាបាលជំងឺថែទាំវេជ្ជសាស្ត្របានទាន់ពេលវេលា ។

### ខ/ ដំណើរការរបបធានារ៉ាប់រងសុខភាព

បន្ទាប់ពីបានអនុវត្តជំហានទី១គឺរបបធានារ៉ាប់រងហានិភ័យការងារ និងដោយយោងតាមការរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិ និងការវិនិយោគពីសំណាក់វិនិយោគិនបរទេសធ្វើឱ្យមានការកើនឡើងកម្មករនិយោជិតដែលបម្រើការងារក្នុងបណ្តាសហគ្រាស គ្រឹះស្ថានរោងចក្រ ទាមទារឱ្យមានការយកចិត្តទុកដាក់ផ្នែកសុខភាពជាចំបងដែលក្នុងនោះចំនួននៃគ្រោះថ្នាក់ដែលបណ្តាលមកពីបញ្ហា

[១៣] ប្រការ ២ នៃប្រកាសលេខ ០២២/០៨ កប.ប្រក ចុះថ្ងៃទី១១ ខែកម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

[១៤] ទំព័រ២៨ ក្នុងរបាយការណ៍ ប.ស.ស ស្តីពីយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៤-២០១៨

សុខភាព និងរបបអាហារកម្មករនិយោជិតផ្ទាល់ ជាពិសេសឥរិយាបទក្នុងការរស់នៅ អនាម័យ កំរិតវប្បធម៌ទាប ការសន្សំសំចៃការអត់ទ្រាំពុំហ៊ានទៅរកសេវាពិនិត្យសុខភាពដែលមានតំលៃខ្ពស់។ បេឡាជាតិរបបសន្តិសុខសង្គម បានដាក់ឱ្យដំណើរការជំហានទី២ គឺរបបធានារ៉ាប់រងសុខភាព[១៥] នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ដើម្បីឱ្យកម្មករនិយោជិតទទួលបាននូវការថែទាំសុខភាព និងការព្យាបាលសុខភាពការពារប្រឆាំងនឹងការប្រថុយប្រថាន និងការចំនាយលើមហន្តរាយផ្នែកសុខភាព និងការប្រឆាំងនឹងការខាតបង់ប្រាក់ចំណូល នៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗ។

**គ/ ការពង្រីក និង អនុវត្តរបបប្រាក់សោធន**

របបប្រាក់សោធនលើវិស័យសាធារណៈសម្រាប់មន្ត្រីរាជការស៊ីវិល អនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ហៅកាត់ថា(ប.ជ.ស)នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ចំពោះរបបសោធនសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ អនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ តារកាលិកនៃផ្នែកសោធនមានជាអាទិ៍ សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក។[១៦] សមាជិកនៃប.ស.សដែលមានអាយុ ៥៥(ហាសិបប្រាំ)ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនជរាភាព ប្រសិនបើបានចុះឈ្មោះក្នុងបញ្ជី នៃ ប.ស.ស ក្នុងចិរវេលាយ៉ាងតិច ២០(ម្ភៃ) ឆ្នាំ និងបានបង់ភាគទានយ៉ាងតិចបំផុត ៦០(ហុកសិប) ខែ ក្នុងកំឡុងពេល ១០(ដប់) ឆ្នាំចុងក្រោយ។ ដូច្នេះ នៅពេលខាងមុខរបបនេះដំណើរការ កម្មករនិយោជិតដែលធ្វើការនៅក្នុងវិស័យឯកជននឹងត្រូវទទួលបានរបបប្រាក់សោធនដូចមន្ត្រីរាជការដែរ ។

[១៥] អនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ

[១៦] មាត្រា៧ នៃច្បាប់ស្តីពីរបបសន្តិសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បបញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២

# ជំពូកទី២
# ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

## ផ្នែកទី១ របបធានារ៉ាប់រងហានិភ័យការងារ

### កថាខណ្ឌទី១ ដំណាក់កាលនៃការទទួលបានរបបធានារ៉ាប់រងហានិភ័យការងារ

#### ក/ បញ្ជិកាសហគ្រាស និងគ្រឹះស្ថាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកតព្វកិច្ចមកចុះបញ្ជិកាសហគ្រាសគ្រឹះស្ថានរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។[១៧] រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានមានដូចតទៅ៖ ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរការត្រូវមកចុះបញ្ជិកាក្នុងរយះពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីប្រកាសចូលជាធរមាន, ចំពោះសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ ត្រូវចុះបញ្ជិកាក្នុងរយះពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ ។

#### ខ/ បញ្ជីកម្មករនិយោជិត

និយោជក ឬម្ចាស់សហគ្រាស ត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតក្នុងសហគ្រាសរបស់ខ្លួនមកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីចុះបញ្ជីការក្នុងបេឡាជាតិរបបសន្តិសុខសង្គម។[១៨]

#### គ/ របាយការណ៍កម្មករនិយោជិត

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់។[១៩]

---

[១៧] ប្រការ១ នៃប្រកាសលេខ០២១/០៨កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជីកាសហគ្រាស គ្រិះស្ថាន និង កម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

[១៨] ប្រការ២ ចំនុច២.១ នៃប្រកាសលេខ០២១/០៨កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជីកាសហគ្រាស គ្រិះស្ថាន និង កម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

[១៩] ប្រការ៥ថ្មី ចំនុច ៥.១ នៃប្រកាសលេខ ២៨៥ កប/ប្រក ស្តីពីការកែសម្រួលប្រកាសលេខ៣,៤,៥នៃប្រកាសលេខ ០២១/០៨កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជីកាសហគ្រាស គ្រិះស្ថាន និង កម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

## កថាខណ្ឌទី២ ការកំណត់ភាគទានហានិភ័យការងារ

### ក/ ការបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) និងមានកម្មករនិយោជិតចាប់ពី៨ (ប្រាំបី)នាក់ឡើងទៅត្រូវមានកតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារជូនបេឡាជាតិរបបសន្តិសុខសង្គម។ ភាគទានផ្នែកហានិភ័យការងារ គឺជាកតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន។ កម្មករនិយោជិត មិនតម្រូវឱ្យមានកតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះទេ។[២០] ការត្រួតពិនិត្យសៀវភៅបើកប្រាក់ និងបញ្ជីឈ្មោះកម្មករនិយោជិតនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់(តារាងបើកប្រាក់បៀវត្សតាមខែនីមួយៗ)បញ្ជីឈ្មោះកម្មករនិយោជិត និងឯកសារពាក់ព័ន្ធផ្សេងៗជូនប.ស.ស ដើម្បីពិនិត្យនៅពេលចាំបាច់។

### ខ/ អត្រាភាគទានហានិភ័យការងារ

អត្រាភាគទានហានិភ័យការងារជាអត្រាឯកភាពដែលត្រូវបានកំណត់ស្មើនឹង 0,៨ ភាគរយនៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត (អត្រាបង់ភាទានសម្រាប់ផ្នែកហានិភ័យការងារ)។ ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយបណ្ណ័បរទេសអត្រានៃប្រាក់ឈ្នួលមធ្យមខាងលើត្រូវ ទូទាត់តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។ ប្រាក់ឈ្នួលប្រចាំខែ គឺប្រាក់ឈ្នួលសរុបដូចមានចែងក្នុងច្បាប់ស្តីពីការងារ។[២១] ប៉ុន្តែ នៅក្នុងកំឡុងពេលដែលមានវិបត្តិសេដ្ឋកិច្ចសកលរាជរដ្ឋាភិបាលកម្ពុជាបានជួយសម្រាលដល់អ្នកវិនិយោគក្នុងផ្នែកកាត់ដេរ និងស្បែកជើងដោយបន្ថយអត្រាភាគទានផ្នែកធានារ៉ាប់រងហានិភ័យការងារពី0,៨ភាគរយ មកត្រឹម0.៥ភាគរយសម្រាប់រយៈពេល២ឆ្នាំគឺឆ្នាំ២00៩និងឆ្នាំ២0១0។ ចំនែកឯផ្នែកភាគទាន0.៣ភាគរយគឺស្ថិតក្នុងបន្ទុករបស់រដ្ឋដែលមានរយៈពេល២ឆ្នាំត្រូវបង់ភាគទានចំនួន ៨,៧១៧,១៥៥,៤៥៩ រៀល។

---

[២០] ប្រការ១ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

[២១] ប្រការ២ ចំនុច២.១ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

*<u>អត្រាបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ</u>*

| ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (គិតជារៀល) | ភាគទានប្រចាំខែសម្រាប់កម្មករនិយោជិត១នាក់(គិតជារៀល) |
|---|---|---|
| ក្រោម ២០០.០០០ | ២០០.០០០ | ១.៦០០ |
| ២០០.០០១-២៥០.០០០ | ២២៥.០០០ | ១.៨០០ |
| ២៥០.០០១-៣០០.០០០ | ២៧៥.០០០ | ២.២០០ |
| ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ | ២.៦០០ |
| ៣៥០.០០១-៤០០.០០០ | ៣៧៥.០០០ | ៣.០០០ |
| ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ | ៣.៤០០ |
| ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ | ៣.៨០០ |
| ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ | ៤.២០០ |
| ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ | ៤.៦០០ |
| ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ | ៥.០០០ |
| ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ | ៥.៤០០ |
| ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ | ៥.៨០០ |
| ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ | ៦.២០០ |
| ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ | ៦.៦០០ |
| ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ | ៧.០០០ |
| ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ | ៧.៤០០ |
| ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ | ៧.៨០០ |
| ១.០០០.០០១ ឡើង | ១.០០០.០០០ | ៨.០០០ |

**គ/ ការបរិច្ឆេទនៃការបង់ភាគទាន**

ការបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូងត្រូវបានកំណត់ក្នុងកំឡុងពេល៣០(សាមសិប) ថ្ងៃ បន្ទាប់ពីការបរិច្ឆេទដែលបេឡាជាតិរបបសន្តិសង្គម(ប.ស.ស) បានចេញ"វិញ្ញាបនបត្របញ្ជិកាសហគ្រាសគ្រឹះស្ថាន"។ការប្រគល់វិញ្ញាបនបត្រខាងលើត្រូវបានបញ្ជាក់ការបរិច្ឆេទដែលសហគ្រាសគ្រឹះស្ថានបានទទួលពីប.ស.ស។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានសម្រាប់ ខែនីមួយៗយ៉ាងយូរបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។[២២]

[២២] ប្រការ៣ថ្មី ចំនុច៣.១ និង ៣.២ នៃប្រកាសលេខ២៩៤ កប/ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួល ប្រការ៣ ប្រការ៤ និង ប្រការ៥ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់

ចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលខកខានមិនបានបង់តាមការបរិច្ឆេទដូចដែលបានកំណត់ក្នុងការបង់ភាគទាន ត្រូវបង់បន្ថែមការប្រចាំខែនូវអត្រាការប្រាក់២ភាគរយនៃចំនួនភាគទានជាក់ស្តែងដែលត្រូវបង់ក្នុងខែនីមួយៗ។

**ឃ/ បែបបទ និងនីតិវិធីនៃការបង់ភាគទាន**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គមដែលស្ថិតនៅក្នុងធានាគារដែលបានកំណត់៖ បង់ផ្ទាល់នៅធនាគារដែលបានកំណត់។ ការបង់ភាគទានរបៀបនេះនិយោជកត្រូវអនុវត្តតាមទម្រង់ "បែបបទបង់ភាគទាន" ឬទម្រង់ "ភ.០១"[២៣]

ការបង់ភាគទានចូលក្នុងគណនីរបស់ ប.ស.ស លេខ៖ ០០០១ ១០៥៦៥៨៨៩ ១៨ នៅធនាគារអេស៊ីលីដា ភីអិលស៊ី[២៤] ឬសេវាកម្មយូនីធី ។ ការចំណាយលើសេវាកម្មនេះ គឺជាបន្ទុកផ្ទាល់របស់និយោជក។ ការបង់តាមសេវាកម្មដទៃផ្សេងទៀតតាមការណែនាំរបស់នាយកបេឡាជាតិរបបសន្តិសុខសង្គម ។

បេឡាជាតិរបបសន្តិសុខសង្គមត្រូវចេញលិខិតបញ្ជាក់អំពី"ការទទួលប្រាក់ភាគទាន" បន្ទាប់ពីបានទទួល "បង្កាន់ដៃបង់ភាគទាន" ឬបន្ទាប់ពីមានការបញ្ជាក់នៅក្នុងរបាយការណ៍ ធានាគារអំពីការបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន។ ចំពោះបង្កាន់ដៃបង់ភាគទានរបាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬឯកសារចាំបាច់នានា និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យប.ស.ស ឬផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬក៏ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

---

អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

[២៣] ប្រការ៤ថ្មី ចំនុចក នៃប្រកាសលេខ២៩៤ កប/ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួល ប្រការ៣ ប្រការ៤ និង ប្រការ៥ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

[២៤] ចំនុច២.I លេខ១១២ បសស/សជណ នៃសេចក្តីជូនដំណឹងស្តីពីនីតិវិធីនៃការបង់ភាគទាន និង ការដោះស្រាយហានិភ័យការងារ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០៨

# ផ្នែកទី២ ហានិភ័យការងារ និង ភាពការលិក

## កថាខណ្ឌទី១ និយមន័យហានិភ័យការងារ

### ក/ សញ្ញាណហានិភ័យការងារ

***គ្រោះថ្នាក់នៅពេលធ្វើការ ឬ ក្នុងពេលធ្វើការ*** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបរាងកាយកម្មករនិយោជិតដោយធ្វើការ ឬក្នុងពេលធ្វើការទោះដោយហេតុយ៉ាងណាក៏ដោយហើយទោះជាមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបរាងកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាសឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី កាន់មុខងារជាអ្វី នៅកន្លែងក៏ដោយ ។

***គ្រោះថ្នាក់ពេលធ្វើដំណើរ*** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារគ្រោះថ្នាក់ដែលធ្លាក់លើរូបរាងកាយនិយោជិត ក្នុងពេលដែលសមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យធ្វើ ។

***ជំងឺវិជ្ជាជីវៈ:*** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារចំពោះជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈដែលទាក់ទងនឹងការងារប្រើកំលាំងកាយប៉ះពាល់ដោយជាតិពុល និងការងារដែលអនុវត្តក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតីដែលនាំឱ្យអ្នកធ្វើការកើតជំងឺផ្សេងៗ ។

### ខ/ ការជូនដំណឹងហានិភ័យការងារ

នៅពេលកម្មករនិយោជិតដែលជាសមាជិកនៃប.ស.ស ទទួលរងគ្រោះថ្នាក់ការងារដោយប្រការណាមួយ ត្រូវជូនដំណឹងជាបន្ទាន់ទៅនាយក ឬអ្នកតំណាងនិយោជក អំពីហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ)ដែលធ្លាក់មកលើខ្លួន។ ក្នុងករណីដែលមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះ ត្រូវធ្លាក់លើសិទ្ធិវន្ត (ជនមានសិទ្ធទទួលបានអត្ថប្រយោជន៍ ដូចជា ប្តី ប្រពន្ធ កូនឬឪពុកម្តាយនៃជនរងគ្រោះ)។[២៥]

បន្ទាប់ពីទទួលដំណឹងអំពីហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ត្រូវជូនដំណឹងទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយះ ពេលយ៉ាងយូរបំផុត៤៨(សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

---

[២៥] ប្រការ១ នៃប្រកាសលេខ១១០ កប/ប្រក ស្តីពីការជូនដំណឹងហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

ការជូនដំណឹងហានិភ័យការងារ ត្រូវធ្វើតាមទម្រង់ "របាយការណ៍ហានិភ័យការងារ"[២៦] ដែលជាលិខិតរដ្ឋបាលរៀបរាប់អំពីព័ត៌មាន សហគ្រាស ព័ត៌មានជនរងគ្រោះ និងព័ត៌មានលំអិតគ្រោះថ្នាក់ការងារដែលនៅក្នុងរបាយការណ៍ នោះក៏មានបញ្ជាក់ផងដែរនៅប្រាក់ឈ្នួល៦(ប្រាំមួយ) ខែចុងក្រោយ ។

❖ គំនូសបំព្រួញរបាយការណ៍ហានិភ័យ




### គ/ ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតឡើងនៅកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យឬមន្ទីពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំនាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើ ត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីដែល គ្រោះថ្នាក់នៅពេលធ្វើការ សមីជន ឬនិយោជកអាចទាមទារការទូទាត់សងលើការចំនាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម។[២៧]

---

[២៦] ប្រការ៣ នៃប្រកាសលេខ១១០ កប/ប្រក ស្តីពីការជូនដំណឹងហានិភ័យការងារចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

[២៧] ប្រការ៤ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

### ឃ/ ការអង្កេតហានិភ័យការងារ

បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្ត/ក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម។ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវធ្វើការអង្កេត នឹងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវការលិកឱ្យបានចាប់រហ័ស។ ចំពោះករណីដែលមានលក្ខណៈស្មុកស្មាញអធិការ ឬអភិបាលសន្តិសុខសង្គម អាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ។ ការចំនាយសម្រាប់ផ្នែកនេះគឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំពត៌មានដែលទាក់ទងនឹងទីកន្លែងពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាមានសមត្ថកិច្ចនៅទីកន្លែងកើតហេតុ។[២៨]

### ង/ ការផ្តល់សេវាថែទាំ និងព្យាបាល

ការព្យាបាលចំពោះកម្មករនិយោជិតដែលរងគ្រោះថ្នាក់ដោយហានិភ័យការងារ ត្រូវប្រព្រឹត្តិនៅក្នុងមន្ទីពេទ្យ ឬមន្ទីពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ មានសិទ្ធទទួលបានការពិនិត្យព្យាបាលនៅតាមបណ្តាលមន្ទីពេទ្យ ឬមន្ទីពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គមផ្អែកលើកិច្ចព្រមព្រៀង រវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីពេទ្យ ឬមន្ទីពហុព្យាបាលសមី។ ក្នុងករណីដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការ ថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀងបេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់ សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវិជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ ។[២៩]

### ច/ មន្ទីពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម

មន្ទីពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម គឺជាមន្ទីពេទ្យដែលចុះកិច្ចសន្យាជាមួយប.ស.ស។ ហើយបច្ចុប្បន្នមន្ទីពេទ្យដែលជាដៃគូសហការផ្នែកហានិភ័យការងារមានមន្ទីពេទ្យ ថ្នាក់ជាតិចំនួន ៤, មន្ទីពេទ្យបង្អែករាជធានី/ខេត្ត/ស្រុក ចំនួន ៦៤, មណ្ឌលសុខភាពរាជធានី/ខេត្ត/ស្រុក ចំនួន ២៥ , និង មូលដ្ឋានសុខាភិបាលឯកជន (មន្ទីពេទ្យ ឬពហុព្យាបាលឯកជន) ចំនួន៤។ ពត៌មានអំពីឈ្មោះមន្ទីពេទ្យ ដូចខាងក្រោមៈ

---

[២៨] ប្រការ៣ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[២៩] ប្រការ៥ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

តារាងទី១ ៖ មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារតាមបណ្ដាលរាជធានី/ខេត្ត

| ល.រ | មូលដានសុខាភិបាលផ្នែកហានិភ័យការងារតាមបណ្ដាលរាជធានី/ខេត្ត | ចំនួនមូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការ |
|---|---|---|
| ១ | មន្ទីពេទ្យថ្នាក់ជាតិ | ០៤ |
| ២ | រាជធានីភ្នំពេញ (លើកលែងមន្ទីពេទ្យថ្នាក់ជាតិ) | ១០ |
| ៣ | ខេត្តកណ្ដាល | ១០ |
| ៤ | ខេត្តកំពង់ស្ពឺ | ០៣ |
| ៥ | ខេត្តស្វាយរៀង | ០២ |
| ៦ | ខេត្តកំពង់ឆ្នាំង | ០២ |
| ៧ | ខេត្តព្រះសីហនុ | ០៥ |
| ៨ | ខេត្តសៀមរាប | ០២ |
| ៩ | ខេត្តបន្ទាយមានជ័យ | ០៣ |
| ១០ | ខេត្តកំពង់ចាម | ០៧ |
| ១១ | ខេត្តត្បូងឃ្មុំ | ០៣ |
| ១២ | ខេត្តក្រចេះ | ០៣ |
| ១៣ | ខេត្តព្រៃវែង | ០៦ |
| ១៤ | ខេត្តតាកែវ | ០៤ |
| ១៥ | ខេត្តកែប | ០១ |
| ១៦ | ខេត្តស្ទឹងត្រែង | ០១ |
| ១៧ | ខេត្តកំពត | ០២ |
| ១៨ | ខេត្តពោធិ៍សាត់ | ០៦ |
| ១៩ | ខេត្តកោះកុង | ០២ |
| ២០ | ខេត្តប៉ៃលិន | ០១ |
| ២១ | ខេត្តបាត់ដំបង | ០៥ |
| ២២ | ខេត្តកំពង់ធំ | ០៣ |
| ២៣ | ខេត្តរតនគិរី | ០២ |
| ២៤ | ខេត្តមណ្ឌលគិរី | ០៣ |
| ២៥ | ខេត្តឧត្តមានជ័យ | ០៣ |
| ២៦ | ខេត្តព្រះវិហារ | ០៤ |
| **សរុបចំនួនមូលដានសុខាភិបាលផ្នែកហានិភ័យការងារមានចំនួន** | | **៩៧** |

### កថាខណ្ឌទី ២ ការទទួលបានតាវកាលិកហានិភ័យការងារ

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបាន "តាវកាលិក"[៣០] ហានិយភ័យការងារ នៅពេលដែល សាមីជនទទួលរងនូវហានិភ័យការងារ។ តាវកាលិកហានិភ័យការងាររួមមាន៖ ការផ្តល់សេវាសង្គ្រោះបន្ទាន់, ការផ្តល់សេវាថែទាំ និងព្យាបាល, ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន[៣១], តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍[៣២], ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ[៣៣],ប្រាក់វិភាជន៍សោហ៊ុយបូជាសព[៣៤], តាវការលិកឧត្តរជីវី[៣៥], និងសេវាបុននីតិសម្បទា[៣៦] ។

#### ក/ ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

ក្នុងកាលទេសៈដែលកម្មករនិយោជិត មិនអាចបំពេញការងារជាធម្មតារបស់ខ្លួនបាន គឺដោយសារការបាត់បង់ផ្នែកណាមួយ និងភាពមិនប្រក្រតីនៃរូបរាងកាយដែលបានជួបឧបទ្ទវហេតុគ្រោះថ្នាក់ការងារក្នុងរយៈពេលកំណត់ជាបណ្តោះអាសន្ន និងការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពបណ្តោះអាសន្ន ហៅថាការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ។

---

[៣០] **តាវកាលិក ៖** គឺជាអត្ថប្រយោជន៍ជាវត្ថុ ជាប្រាក់ ឬជាសេវាដែលផ្តល់ឱ្យសមាជិកនៃប.ស.ស នៅពេលចាស់ជរាទុព្វលភាព និង ពេលទទួលរងហានិភ័យការងារ

[៣១] **ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន៖** ត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីការបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឲ្យទទួលរងនូវហានិភ័យការងារ ដែលប្រាក់នេះស្មើនឹង ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

[៣២] **តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ៖** ត្រូវផ្តល់ជូនកម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលតិចជាង២០ភាគរយមានសិទ្ធទទួលបានប្រាក់វិភាជន៍ និងចាប់ពី២០ ភាគរយឡើងមានសិទ្ធទទួលបានប្រាក់ធនលាភសម្រាប់បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ។

[៣៣] **ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ ៖** កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលតម្រូវឱ្យមានអ្នកចាំថែរក្សា មានសិទ្ធទទួលការឧបត្ថមបន្ថែមស្មើនឹង៥០ភាគរយ នៃប្រាក់ធនលាភរបស់ជនរងគ្រោះ

[៣៤] **ប្រាក់វិភាជន៍សោហ៊ុយបូជាសព ៖** ក្នុងករណីទទួលរងហានិភ័យការងារ រហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវផ្តល់ប្រាក់វិភាជន៍សោហុយបូជាសព ដែលមានចំនួន៩,០០០,០០០ រៀល

[៣៥] **តាវការលិកឧត្តរជីវី ៖** គឺជាប្រាក់ធនលាភដែលផ្តល់ឱ្យសិទ្ធវន្ត នៃជនរងគ្រោះដែគ្រោះថ្នាក់ការងាររហូតបាត់បង់ជីវិត។ សិទ្ធវន្ត ដូចជាប្រពន្ធឬជាប្តី កូនឬ ឪពុកម្តាយ ចំពោះសិទ្ធវន្ត ជាប្រពន្ធ ឬជាប្តីនៃជនរងគ្រោះត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ហើយសិទ្ធនេះនឹងត្រូវបានរលាយនៅពេលដែលសមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី

[៣៦] **សេវាបុននីតិសម្បទា ៖** កម្មករនិយោជិតដែលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិត្រៃយ៍ មានសិទ្ធទទួលបានឧបករណ៍ ឬ អវយវៈសិប្បនិម្មិត សេវាសម្របសម្រួលមុខងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ

- ❖ រយៈពេលនៃការបាត់បង់សមត្ថភាពបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅៈ[៣៧]
  - រយៈពេលនៃការព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
  - រយៈពេលនៃការសម្រាកព្យាបាលក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។
- ❖ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ មានសិទ្ធទទួលបានតាវកាលិក ពីបេឡាជាតិរបបសន្តិសុខសង្គមនូវៈ
  - ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
  - ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំជនរងគ្រោះ ក្នុងរយៈពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬ មន្ទីរពហុព្យាបាល ។

ចំពោះប្រាក់ឈ្នួលថ្ងៃផ្អាកការងារដំបូងរបស់ជនរងដែលទទួលរងគ្រោះថ្នាក់ការងារត្រូវស្ថិតនូវក្នុងបន្ទុករបស់និយោជក។[៣៨] ចំណែកឯប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង៧០(ចិតសិប)ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនូវមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលត្រូវស្មើនឹង៥០(ហាសិប)ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។[៣៩]ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ។[៤០]

---

[៣៧] ប្រការ៧ថ្មី ចំណុច៧.១ និង ចំណុច៧.២ នៃប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៧ និង ប្រការ៨ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[៣៨] ប្រការ៧ថ្មី ចំណុច៧.៣ នៃប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីតាវកាលិកហានិភ័យការងារ

[៣៩] ប្រការ៧ថ្មី ចំណុច៧.៤ នៃប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ស្តីពីតាវកាលិកហានិភ័យការងារ

[៤០] ប្រការ៧ថ្មី ចំណុច៧.៥ នៃប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ តាវកាលិកហានិភ័យការងារ

❖ **ការគណនាតាវកាលិក**

$$\text{ប្រាក់ឈ្នួលមធ្យម} = \frac{\text{ប្រាក់ឈ្នួលជាប់ភាគទាន៦ខែមុនខែគ្រោះថ្នាក់}}{៦}$$

$$\text{ប្រាក់ឈ្នួលជាប់ភាគទាន} = \frac{\text{ប្រាក់ឈ្នួលមធ្យម}}{៣០}$$

**ប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ = ៧០% × ប្រាក់ឈ្នួលជាប់ភាគទាន**

**ប្រាក់បំណាច់ប្រចាំថ្ងៃរបស់អ្នកថែទាំជំងឺ = ៥០% × ប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ**

*បញ្ជាក់ ប្រាក់បំណាច់ប្រចាំថ្ងៃត្រូវបានផ្តល់ឱ្យចាប់ពីថ្ងៃទីពីរបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលរងហានិភ័យការងារ(សម្រាកព្យាបាលមុខរបួសក្នុងមន្ទីរពេទ្យ និងក្រោយមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា)

**ឧទាហរណ៍៖** **មករា** បានទទួលរងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការបណ្តាលឱ្យសម្រាកព្យាបាលនៅមន្ទីពេទ្យរយៈពេល៦ថ្ងៃ។ ប្រាក់ឈ្នួលរបស់មករាគឺ១,១៥០,០០០រៀលក្នុងមួយខែ នៅក្នុង រយៈពេល៦ ខែចុងក្រោយមុនពេលដែលគាត់ទទួលរងគ្រោះថ្នាក់ ។

**សំនួរ ១.តើគាត់ទទួលបានតាវកាលិកប្រាក់បំណាច់ពី ប.ស.ស ដែររឺទេ ?**

**២. បើមានតើគាត់ទទួលបានប្រាក់បំណាច់សរុបចំនួនប៉ុន្មាន ?**

**ចម្លើយ ៖ ១. គាត់មានសិទ្ធទទួលបានតាវកាលិកប្រាក់បំណាច់ពី ប.ស.ស ។**

**២. គណនាប្រាក់បំណាច់របស់មករា**

- ប្រាក់ឈ្នួលរបស់មករាដែលទទួលបានក្នុងមួយខែៗ ចំនួន ១,១៥០,០០០ រៀល ថេរក្នុងរយៈពេល៦ ខែមុនគ្រោះថ្នាក់ ហើយប្រាក់ឈ្នួលមធ្យមដែលជាប់ភាគទាន របស់គាត់គឺ ១,០០០,០០០ រៀល ។ ដូចនេះ ប្រាក់ឈ្នួលមធ្យមរបស់គាត់ក្នុងរយៈពេល៦ខែចុងក្រោយ គឺ ៖

១,០០០,០០០ រៀល × ៦ (ខែ) = ១,០០០,០០០ រៀល
៦

- **គណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

  = ១,០០០,០០០ / ៣០ (ថ្ងៃ) = ៣៣,៣០០ រៀល

- **គណនាប្រាក់បំណាច់ប្រចាំថ្ងៃ**

  = ០,៧ × ៣៣,៣០០ រៀល = ២៣,៣០០ រៀល (ក្នុងមួយថ្ងៃ)

**ដូចនេះ ប្រាក់បំណាច់សរុបដែលមករាទទួលបានពីប.ស.ស សម្រាប់ថ្ងៃទី២,៣,៤,៥ និង ៦ គឺ ៖**

= ២៣,៣៣៣ រៀល × ៥ (ថ្ងៃ) = **១១៦,៧០០ រៀល**

## ខ/ ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ភាគរយ មានសិទ្ធទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍ត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់ ហើយគិតតាមរូបមន្តដូចខាងក្រោម៖[៤១]

**វបក = បឈម × កបក × ២០% មតប**

**វបក** : វិភាជន៍បាត់សមត្ថភាពការងារ

**បឈម** : ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ

**កបក** : កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ

**មតប** : មេគុណតំលៃបច្ចុប្បន្ន

[៤១] ប្រការ៨ថ្មី នៃប្រកាសលេខ២៣៣ កប/ប្រក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និង ប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាព ចាប់ពី២០% ឡើងមានសិទ្ធទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ ប្រាក់ធនលាភសម្រាប់ការបាត់សមត្ថភាពការងារជាងអចិន្ត្រៃយ៍ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម៖[៤២]

| ធន = បឈម × [កបក-១/៥កបក] |
|---|

**ធល** : ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

**បឈម** : ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ

**កបក** : កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ

ក្នុងរយៈពេលមួយឆ្នាំម្តង ជនរងគ្រោះត្រូវពិនិត្យសុខភាព និងសមត្ថភាពការងារឡើងវិញ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារ ហើយជនរងគ្រោះដែលទទួលបានធនលាភនោះ ត្រូវមានកតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់ ប.ស.ស ។

**ឧទាហរណ៍** : សុខា ជាកម្មការីកាត់ដេរ បម្រើការនៅរោងចក្រស្បែកជើងមួយកន្លែងនៅរាជធានីភ្នំពេញ។ នៅថ្ងៃកើតហេតុនាង បានជួនឧបទ្ទវហេតុនៅកន្លែងធ្វើការបណ្តាលឱ្យកាត់ប្រអប់ដៃខាងឆ្វេងរបស់នាងធ្វើឱ្យគាត់បាត់បង់កម្រិតសមត្ថភាពការងារ៦០%។ ប្រាក់ឈ្នួលរបស់សុខា ក្នុង១ខែ ក្នុងរយៈពេល៦ខែ ចុងក្រោយមុនពេលគាត់រងគ្រោះថ្នាក់គឺ ៩៦០,០០០ រៀល។ តើគាត់ទទួលបានប្រាក់ធនលាភចំនួនប៉ុន្មាន?

**ចម្លើយ ៖ រកប្រាក់ធនលាភដែលគាត់ទទួលបាន**

ដោយប្រាក់ឈ្នួលរបស់ជនរងគ្រោះគឺ៩៦០,០០០រៀល នាំឱ្យប្រាក់ឈ្នួលជាប់ភាគទាន គឺស្មើនឹង ៩៧៥,០០០ រៀល

⇨ **គណនារកប្រាក់ឈ្នួលមធ្យម**

= (៩៧៥,០០០រៀល × ៦ ) / ៦ = ៩៧៥,០០០ រៀល

⇨ **រកប្រាក់ឈ្នួលប្រចាំថ្ងៃប្រចាំថ្ងៃ**

[៤២] ប្រការ៨ថ្មី ចំណុច៨.២ នៃប្រកាសលេខ២៣៣ កប/ប្រក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និង ប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារ

= ៩៧៥,០០០រៀល / ៣០ ថ្ងៃ = ៣២,៥០០ រៀល

⇨ **យើងបានប្រាក់ធនលាភ**

= ៣២,៥០០ រៀល × ០,៧ × [ ០,៦ - (១/៥×០,៦)]

= **១០,៩២០ រៀល**

**គ/ ការទទួលបានតាវកាលិកចំពោះសមាជិកជនរងគ្រោះ**

- **តាវកាលិកសម្រាប់អ្នកថែទាំ**

ក្នុងករណីកម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដែលតម្រូវឱ្យមានអ្នកចាំថែរក្សា មានសិទ្ធទទួលបានការឧបត្ថមបន្ថែមស្មើនឹង៥០(ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ។ សិទ្ធទទួលបានអ្នកចាំថែរក្សា ត្រូវសម្រេចដោយនាយកប.ស.ស អនុលោមតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ។[៤៣]

- **តាវកាលិកឧត្តរជីវី**

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធវន្តនៃជនរងគ្រោះដែលសិទ្ធវន្តនៃជនរងគ្រោះ មានដូចជា ប្តី ឬប្រពន្ធ កូន នឹងឪពុកម្តាយ ឬមនុស្សចាស់ជរា នៅក្នុងបន្ទុកសិទ្ធវន្តរបស់ជនរងគ្រោះដោយហានិភ័យការងារដែលត្រូវទទួលបានតាវកាលិក ឧត្តរជីវី ត្រូវបានកំណត់ដូចខាងក្រោម៖[៤៤]

+ ប្តី ឬប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអាត្រានុគោលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្តី ឬ ប្រពន្ធដែលជាសមាជិកនៃប.ស.ស ។
+ កូនដែលមានអាយុត្រឹម១៨ឆ្នាំចុះដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាពដូចជា៖ កូននៃសហាពន្ធ័ដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានការចុះបញ្ជីអត្រានុគោលដ្ឋានត្រឹមត្រូវ។ ក្នុងករណីការលែងលះឬ មរណភាពនៃប្តី ឬប្រពន្ធ កូននៃ

[៤៣] ប្រការ៩ថ្មី នៃប្រកាសលេខ១៥០ កប/ប្រក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៧ និង ប្រការ៩ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[៤៤] មាត្រា៣៩ នៃអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

អាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ។ កូនចិញ្ចឹមរបស់ជនរងគ្រោះ ដែលស្ថានភាពរបស់កូនចិញ្ចឹមត្រូវអនុលោមតាមច្បាប់។

+ ឪពុកម្ដាយ ឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះ។ សិទ្ធទទួលបានធនលាភនៃសិទ្ធវន្ត ត្រូវរំលាយចោលនៅពេលដែលសមីជន ទទួលមរណភាព ។

- **តាវកាលិកឧត្តរជីវី ត្រូវផ្ដល់ឱ្យសិទ្ធវន្តតាមអត្រាដូចខាងក្រោម ៖**[៩៥]

⇨ ក្នុងករណីសិទ្ធវន្ត មានរួមទាំងប្រពន្ធ ឬប្ដី កូន នឹងឪពុកម្ដាយ ឬមនុស្ស ចាស់ជរា នៅក្នុងបន្ទុក

- ប្រពន្ធ ឬ ប្ដី = ៣/៥ × ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ៧ % បឈម

⇨ ក្នុងករណីសិទ្ធវន្ត មានតែប្រពន្ធ ឬ ប្ដី និង/ឬ កូន

- ប្រពន្ធ ឬ ប្ដី = ៣/៥ × ៧០% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៧០% បឈម

⇨ ក្នុងករណីសិទ្ធវន្តមានតែឪពុកម្ដាយ ឬ មនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

⇨ ក្នុងករណីសិទ្ធវន្តមានតែកូន និង ឪពុកម្ដាយ ឬ មនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

⇨ ក្នុងករណីសិទ្ធវន្តមានតែប្រពន្ធ ឬ កូន និងឪពុកម្ដាយ ឬ មនុស្សចាស់ជរា

- ប្រពន្ធ ឬ ប្ដី = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

[៩៥] ប្រការ១១ ចំណុច ១១.២ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ

### ឃ/ សេវាបុននីតិសម្បទា

កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធទទួលបានឧបករណ៍ ឬអវយវសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍មានសិទ្ធទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[៤៦]

### ង/ ការទាមទារតាវកាលិក

កម្មករនិយោជិតដែលរងហានិភ័យការងារ អាចទាមទារតាវកាលិកត្រូវធ្វើឡើងតាមទម្រង់បែបបទផ្សេងៗពីគ្នាដែលមានចែងក្នុងប្រកាសលេខ១០៩កប/ប្រកស្តីពីតាវកាលិកហានិភ័យការងារ៖[៤៧]

| ល.រ | តាវកាលិក | ទំរង់ | អ្នកមានសិទ្ធទាមទារ |
|---|---|---|---|
| ១ | តាវកាលិកថែទាំ និង ព្យាបាល | ឧបសម្ព័ន្ធ ៣.០២ | មន្ទីពេទ្យ,ជនរងគ្រោះ ឬ និយោជក |
| ២ | តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | ឧបសម្ព័ន្ធ ៣.០៣ | ជនរងគ្រោះ ឬ តំណាង |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ | ឧបសម្ព័ន្ធ ៣.០៤ | ជនរងគ្រោះ ឬ តំណាង |
| ៤ | តាវកាលិកឧត្តរជីវី | ឧបសម្ព័ន្ធ ៣.០៥ | សិទ្ធវន្តនៃជនរងគ្រោះ ឬ តំណាង |
| ៥ | វិភាជន៍បូជាសព | ឧបសម្ព័ន្ធ ៣.០៦ | សិទ្ធវន្តនៃជនរងគ្រោះ ឬ តំណាង |

[៤៦] ប្រការ១២ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
[៤៧] ប្រការ១៣ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

សិទ្ធនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់ សុពលភាពក្នុងរយៈពេល១(មួយ)ឆ្នាំ។ ចំពោះសិទ្ធក្នុងការទាមទារប្រាក់ធនលាភត្រូវអស់ សុពលភាពត្រឹមរយៈពេល ៥(ប្រាំ)ឆ្នាំ ។[៤៨]

### ច/ ការដោះស្រាយវិវាទ

គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃប.ស.ស(ដ.វ.ប)បង្កើតឡើងដោយ ប្រកាសលេខ ១៧៧ កប/ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ជាគណៈកម្មការត្រីភាគី ក្នុងនោះរួមមានក្រសួង ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ(តំណាងរដ្ឋាភិបាល), តំណាងនិយោជក និងតំណាងកម្មករ និយោជិត ។

គណៈកម្មការនេះមានតួនាទីភារកិច្ច ផ្សះផ្សាវិវាទដែលទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គម ដូចជាបណ្ដឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងការមិនយល់ព្រម ឬភាពមិន ត្រឹមត្រូវក្នុងការផ្ដល់តាវកាលិករបបសន្តិសុខសង្គម, បណ្ដឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប. ស.ស ទាក់ទងនឹងភាពមិនប្រក្រតីនៃការផ្ដល់សេវារបបសន្តិសុខសង្គម, បណ្ដឹងតវ៉ារបស់កម្មករ និយោជិតសមាជិក ប.ស.ស ចំពោះការខកខានរបស់និយោជកមិនរាយការណ៍ដើម្បីចុះឈ្មោះខ្លួន ក្នុងប.ស.ស, បណ្ដឹងតវ៉ារបស់និយោជកចំពោះការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ ឬបទបញ្ញាជា ធរមានរបស់មន្រ្តី ប.ស.ស និងបណ្ដឹងតវ៉ាផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តបេឡា ជាតិរបប សន្តិសុខសង្គម។[៤៩]

---

[៤៨] ប្រការ១៣ ចំណុច១៣.៥ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យ ការងារ

[៤៩] ប្រការ២ នៃប្រកាសលេខ១៧៧ កប/ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹងនៃ ប.ស.ស

# ជំពូកទី៣
# របបធានារ៉ាប់រងថែទាំសុខភាព
## ផ្នែកទី១ សេវាថែទាំសុខភាព

### កថាខណ្ឌទី១ ការអនុវត្តរបបធានារ៉ាប់រងសុខភាព

ដំណើរការធានារ៉ាប់រងសុខភាព ត្រូវបានកំណត់ក្នុងគោលដៅទី២នៃយុទ្ធសាស្ត្រគាំពារសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០១៤-២០១៨ ដែលក្នុងនោះបានបង្ហាយរបបធានារ៉ាប់រងហានិភ័យការងារ និងរបបធានារ៉ាប់រងសុខភាព ដោយសារសុខភាពរបស់កម្មករនិយោជិត មិនអាចទទួលត្រឹមតែការគាំពារជំងឺ ឬគ្រោះថ្នាក់ដែលបណ្តាលមកពីការងារប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានការពារជំងឺ និងគ្រោះថ្នាក់ទូទៅដែលមិនពាក់ពន្ធ័នឹងការងារ ផងដែរ។

ករណីសន្លប់កម្មករនិយោជិត ក៏មានគ្រោះថ្នាក់មួយចំនួនទៀតដែលមិនមែនជាគ្រោះថ្នាក់ការងារបានទៅទទួលសេវាព្យាបាលនៅតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងក៏ដូចជាបានរាយការណ៍ និងមិនបានរាយការណ៍មក ប.ស.ស ទាក់ទងនឹងបញ្ហាសុខភាពស្ថិតក្នុងស្ថានភាពមួយគួឱ្យព្រួយបារម្ភ។ ស្ថានភាពទាំងនេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព និងការរស់នៅរបស់កម្មករនិយោជិតដែលត្រូវចំណាយខ្ពស់សម្រាប់ការទូទាត់ថ្លៃសេវាវេជ្ជសាស្ត្រ ហើយនាំឱ្យមានការប៉ះពាល់ដល់ស្ថានភាពគ្រួសារជាដើម។ ការចាប់ផ្តើមពីជំហានអនុវត្តគម្រោងធានារ៉ាប់រងសុខភាពសាកល្បងដែលមានសហគ្រាសចំនួន១១និងកម្មករនិយោជិតប្រមាណជា៧០០០នាក់នៅរាជធានីភ្នំពេញ។ ជាក់ស្តែងប.ស.សបានដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៦ គន្លងមក។[៥០]

### កថាខណ្ឌទី២ នីតិវិធី និងបែបបទនៃការចុះបញ្ជិកាជាសមាជិក ប.ស.ស

#### ក/ ចំពោះកម្មករនិយោជិត

ដើម្បីក្លាយជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម កម្មករនិយោជិត ត្រូវចុះបញ្ជិកា ជាមុនសិន។ ការចុះឈ្មោះក្នុងបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើតាមទម្រង់សលាប័ត្រព័ត៌មានសម្រាប់

[៥០] ប្រកាសលេខ០៩៣/១៦ ស្តីពីការកំណត់ដំណាក់កាល និង កាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ផ្តល់អត្តសញ្ញាណសមាជិកប.ស.ស។ រីឯឯកសារដែលត្រូវភ្ជាប់មកជាមួយដើម្បីចុះបញ្ជិកាកម្មករនិយោជិតរួមមាន៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬ សៀវភៅគ្រួសារ ឬប័ណ្ណស្នាក់នៅ ឬឯកសារផ្សេងៗដែលមានតម្លៃស្មើ។[៥១] ប.ស.ស នឹងផ្តល់ លេខអត្តសញ្ញាណ និងបណ្ណ័សមាជិកប.ស.ស ជូនដល់កម្មករនិយោជិតតាមរយៈនិយោជក ឬអ្នកតំណាង។ ដើម្បីទទួលបានសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រកម្មករនិយោជិតទាំងអស់ត្រូវ បំពេញតាមលក្ខខណ្ឌដូចតទៅ៖[៥២]

- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ របបថៃទាំសុខភាព
- បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម
- បានបង់ភាគទានសម្រាប់ផ្នែកថៃទាំសុខភាពក្នុងរយៈពេល២ខែជាប់ៗគ្នា ឬបានបង់ភាគទានយ៉ាងតិច ៦ខែ ក្នុងកំឡុងពេល១២ខែចុងក្រោយគិតរហូតមកទល់ខែ ដែលមានបញ្ហាសុខភាព ឬមាតុភាព ។

**ខ/ ចំពោះសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជិកានៅប.ស.ស[៥៣]**

- ការចុះឈ្មោះក្នុងបញ្ជិកាកម្មករនិយោជិតត្រូវធ្វើតាមទម្រង់សលាប័ត្រពត៌មានសម្រាប់ផ្តល់អត្តសញ្ញាណសមាជិក ប.ស.ស
- ប.ស.ស នឹងផ្តល់កាលបរិច្ឆេទសម្រាប់ការចុះកំណត់អត្តសញ្ញាណសមាជិក ប.ស.ស នៅតាមមូលដ្ឋាន សហគ្រាស គ្រឹះស្ថាន
- នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមានកតព្វកិច្ចបំពេញព័ត៌មានកម្មករនិយោជិតឱ្យបានត្រឹមត្រូវនូវក្នុងសលាប័ត្រព័ត៌មានដោយភ្ជាប់មកជាមួយនូវឯកសារដូចជាអត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬបណ្ណ័ស្នាក់នៅ ឬឯកសារផ្សេងៗដែលមានតម្លៃស្មើ

---

[៥១] ចំណុច ក នៃសេចក្តីណែនាំលេខ ៦៩/១៥ ប.ស.ស ស្តីពីនីតិវិធី និង បែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥

[៥២] ប្រការ៦ ចំណុច៦.១ នៃប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកថៃទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

[៥៣] ចំណុច ក. នៃសេចក្តីណែនាំលេខ៦៩/១៥ ប.ស.ស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីនីតិវិធី និង បែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម

- ប.ស.ស នឹងផ្តល់អត្តសញ្ញាណឬបណ្ណ័សមាជិកប.ស.សជូនបុគ្គលិកកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង ។

**គ/ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី[៥៨]**

- ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នានឹងការចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន
- សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី៥០នាក់ឡើងទៅ ប.ស.ស នឹងផ្តល់កាលបរិច្ឆេទចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត
- សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតក្រោម៥០នាក់ ប.ស.ស នឹងផ្តល់កាលបរិច្ឆេទ និងអញ្ជើញនិយោជកឬតំណាង និងកម្មករនិយោជិត មកកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅប.ស.ស(ដោយភ្ជាប់មកជាមួយនូវឯកសារ) បន្ទាប់ពីបានបំពេញសលាប័ត្រព័ត៌មានរួច
- ប.ស.ស នឹងផ្តល់លេខអត្តសញ្ញាណ នឹងបណ្ណ័សមាជិកប.ស.ស ជូនកម្មករនិយោជិតតាមរយ: និយោជក ឬអ្នកតំណាង ។

**ឃ/ សហគ្រាសដែលបានចុះបញ្ជីជាមួយប.ស.ស**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)បានដាក់ឱ្យដំណើរការរបបថែទាំសុខភាពប្រកបដោយផ្លែផ្កា។ ដោយយោងតាមរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) បានចុះកំណត់អត្តសញ្ញាតិកម្មករនិយោជិត ត្រឹមខែធ្នូ ឆ្នាំ២០១៦ បានចំនួន ៦០៣សហគ្រាស មានកម្មករនិយោជិតចំនួន៦០០ ៨៣១ នាក់ ក្នុងនោះស្រី៥០៤ ៥៥៦នាក់ ។

[៥៨] ចំណុច ខ. នៃសេចក្តីណែនាំលេខ៦៩/១៥ ប.ស.ស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីនីតិវិធី និង បែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម

## ផ្នែកទី២ មន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស

### កថាខណ្ឌទី១ មូលដ្ឋានសុខាភិបាលជាដៃគូ

មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវមានកតព្វកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)ដោយអនុវត្តតាមទម្រង់នៃកិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន១ (សម្រាប់មណ្ឌលសុខភាព) ឧបសម្ព័ន២(សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣) និងឧបសម្ព័ន៣(សម្រាប់មន្ទីរពេទ្យជាតិ)

រីឯមូលដ្ឋានសុខាភិបាលឯកជន អាចចុះកិច្ចព្រមព្រៀងជាមួយប.ស.ស បានលុះត្រាតែមានអាជ្ញាបណ្ណ័ទទួលស្គាល់ដោយក្រសួងសុខាភិបាល នឹងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពសេវាពីប.ស.ស ។

ប.ស.ស អាចចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលដោយផ្អែកលើសេចក្តីត្រូវការចាំបាច់ទីតាំងភូមិសាស្ត្រ និងស្ថានភាពមូលដ្ឋានសុខាភិបាលព្រមទាំងមានធនធានហេដ្ឋារចនាសម្ព័ន្ធសមស្រប ឬគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាសុខាភិបាលឱ្យមានគុណភាពក្នុងនោះរួមមានៈ

- អគារសមរម្យ និងបរិស្ថានអនាម័យល្អ
- ឱសថ សម្ភារៈ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយចាំបាច់នានាសម្រាប់គាំទ្រធ្វើរោគវិនិច្ឆ័យ ការផ្តល់ការព្យាបាល និងថែទាំតាមវិធានបទបញ្ជា និងអាជ្ញាបណ្ណ័ផ្សេងៗ របស់ក្រសួងសុខាភិបាល
- បុគ្គលិកសុខាភិបាល មានសមត្ថភាពបច្ចេកទេស ក្រមសិលធម៌ និងមានចំនួនសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល។[៥៥]

មន្ទីរពេទ្យ ឬមន្ទីពហុព្យាបាលដែលបេឡាជាតិរបបសន្តិសុខសង្គមទទួលស្គាល់សម្រាប់ការព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈដែលបណ្តាលមកពីហានិភ័យការងារ ក៏ដូចជារបបថែទាំសុខភាពមាននៅរាជធានីភ្នំពេញ និងនៅតាមបណ្តាលរាជធានី/ខេត្ត។ នៅរាជធានីភ្នំពេញមានៈ មន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យមិត្តខ្មែរ-សូវៀត មន្ទីរពេទ្យព្រះកុសមៈ និងមន្ទីរពេទ្យព្រះកេតុមាលា។ តាមបណ្តាលខេត្ត មានមន្ទីរពេទ្យពីរកម្រិតគឺ ១-មន្ទីរពេទ្យបង្អែកកម្រិត៣ (ថ្នាក់រាជធានី ខេត្ត), ២-មន្ទីរពេទ្យបង្អែកកម្រិត២ (ថ្នាក់ក្រុង ស្រុក ខណ្ឌ) ។

[៥៥] ប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ២៩១ កប/ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់និង ការផ្តល់សេវាសុខភាព រវាងបេឡាជាតិរបបសន្តិសុខសង្គម និង មូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាពនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសុខាភិបាល ។

ដោយឡែកចំពោះករណីសង្គ្រោះបន្ទាន់ កម្មករនិយោជិតអាចជ្រើសរើស ឬត្រូវសង្គ្រោះនៅមន្ទីពេទ្យ ឬមន្ទីរព្យាបាលដែលស្ថិតនៅជិតកន្លែងគ្រោះថ្នាក់បំផុត។ មន្ទីពេទ្យ ឬមន្ទីព្យាបាលដទៃទៀត អាចធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គមតាមសេចក្តីត្រូវការជាក់ស្តែង។

ក/ កម្រិតនៃការផ្តល់សេវាសុខភាព

ក/១ មន្ទីពេទ្យកម្រិតជាតិ (NH)

មន្ទីពេទ្យជាតិទទួលពិនិត្យជំងឺដូចជា៖ ពិនិត្យជំងឺក្រៅ វះកាត់តូច សង្គ្រោះបន្ទាន់ សលសាស្ត្រ វះកាត់ធំ វះកាត់មធ្យម ជំងឺទូទៅមនុស្សពេញវ័យ សម្រាលកូន រោគស្ត្រី រំលូត/រលូតកូន ជំងឺទូទៅ និងជំងឺរបេង ។

ក/២ មន្ទីពេទ្យបង្អែកកម្រិត៣ (រាជធានី ខេត្ត-CPA3)

មន្ទីពេទ្យបង្អែកកម្រិត៣ ទទួលពិនិត្យជំងឺដូចជា ៖ ពិនិត្យជំងឺក្រៅ វះកាត់តូច សង្គ្រោះបន្ទាន់ សលសាស្ត្រ វះកាត់ធំ ជំងឺទូទៅមនុស្សពេញវ័យ សម្រាលកូន រោគស្ត្រី រំលូតកូន/រលូតកូន ជំងឺទូទៅ និងជំងឺរបេង ។

ក/៣ មន្ទីពេទ្យបង្អែកកម្រិត២ (ក្រុង ស្រុក ខណ្ឌ-CPA2)

មន្ទីពេទ្យជាតិទទួលពិនិត្យជំងឺដូចជា៖ ពិនិត្យជំងឺក្រៅ វះកាត់តូច សង្គ្រោះបន្ទាន់ សលសាស្ត្រ វះកាត់ធំ ជំងឺទូទៅមនុស្សពេញវ័យ សម្រាលកូន រោគស្ត្រី រំលូតកូន/រលូតកូន។

ក/៤ មន្ទីពេទ្យបង្អែកកម្រិត១ (ឃុំ សង្កាត់-CPA1)

មន្ទីពេទ្យជាតិទទួលពិនិត្យជំងឺដូចជា៖ ពិនិត្យជំងឺក្រៅ សង្គ្រោះបន្ទាន់ និងបញ្ជូន វះកាត់តូច សេវាបង្កាសុខភាព សម្រាលកូន ពន្យាកំណើតរយៈពេលវែង។[៥៦]

[៥៦] ប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

## ខ/ តារាងស្ថិតិមន្ទីពេទ្យ មន្ទីពេទ្យបង្អែក និងមណ្ឌលសុខភាពនៅរាជធានី/ខេត្ត

បញ្ជីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសង្គម សម្រាប់ថែទាំសុខភាពគិតត្រឹមខែមេសា ឆ្នាំ២០១៧។ ក្នុងនោះ មន្ទីពេទ្យថ្នាក់ជាតិ មានចំនួន ៣, មន្ទីពេទ្យបង្អែករាជធានី/ខេត្ត/ស្រុកមានចំនួន១០០, មណ្ឌលរាជធានី/ខេត្ត/ស្រុក មានចំនួន ១១២១, សរុបមូលដ្ឋានសុខាភិបាលចំនួន១២២៤ ។

តារាងទី២ ៖ មូលដ្ឋានសុខាភិបាលផ្អែកថែទាំសុខភាពតាមបណ្តាលរាជធានី/ខេត្ត(ត្រឹមឆ្នាំ២០១៦)

| ល.រ | មូលដ្ឋានសុខាភិបាលតាមបណ្តាលរាជធានី/ខេត្ត | ចំនួនមូលដ្ឋានសុខាភិបាល |
|---|---|---|
| ១ | មន្ទីពេទ្យថ្នាក់ជាតិ | ០៣ |
| ២ | រាជធានីភ្នំពេញ(លើកលែងមន្ទីពេទ្យថ្នាក់ជាតិ) | ៤៧ |
| ៣ | ខេត្តកណ្តាល | ១០៨ |
| ៤ | ខេត្តកំពង់ស្ពឺ | ៥៨ |
| ៥ | ខេត្តស្វាយរៀង | ៤៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤៤ |
| ៧ | ខេត្តព្រះសីហនុ | ១៦ |
| ៨ | ខេត្តសៀមរាប | ៩៥ |
| ៩ | ខេត្តបន្ទាយមានជ័យ | ៧២ |
| ១០ | ខេត្តកំពង់ចាម | ៩៤ |
| ១១ | ខេត្តត្បូងឃ្មុំ | ៧២ |
| ១២ | ខេត្តក្រចេះ | ៣៣ |
| ១៣ | ខេត្តព្រៃវែង | ១១៣ |
| ១៤ | ខេត្តតាកែវ | ៨៥ |
| ១៥ | ខេត្តកែប | ០៥ |
| ១៦ | ខេត្តស្ទឹងត្រែង | ១៣ |

| | | |
|---|---|---|
| ១៧ | ខេត្តកំពត | ៦៦ |
| ១៨ | ខេត្តពោធិ៍សាត់ | ៤៤ |
| ១៩ | ខេត្តកោះកុង | ១៥ |
| ២០ | ខេត្តប៉ៃលិន | ០៧ |
| ២១ | ខេត្តបាត់ដំបង | ៨១ |
| ២២ | ខេត្តកំពង់ធំ | ៥៥ |
| ២៣ | ខេត្តរតនគិរី | ១៨ |
| ២៤ | ខេត្តមណ្ឌលគិរី | ១៣ |
| ២៥ | ខេត្តឧត្តរមានជ័យ | ១៨ |
| ២៦ | ខេត្តព្រះវិហារ | ១ |
| | **សរុបមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាពតាមបណ្តារាជធានី/ខេត្ត** | **១២២៤** |

**គ/ ប្រភពផ្តល់ និងទទួលព័ត៌មានរបស់ប.ស.ស**

សម្រាប់ការផ្តល់ព័ត៌មាន និងទទួលបានព័ត៌មានត្រលប់ពីសមាជិកពាក់ព័ន្ធការប្រើប្រាស់សេវា និងផ្តល់សេវារបស់ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលជាដៃគូ ទាក់ទងនិងបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងដំណើរការនៃការផ្តល់ និងការទទួលសេវាព្រមទាំងនីតិវិធីនៃការទទួលសេវាផ្សេងៗ នៅតាមមូលដ្ឋានសុខាភិបាល ឬការផ្តល់សេវាមិនច្បាស់លួរបស់ភ្នាក់ងារប.ស.ស ហើយប្រជាពលរដ្ឋ និងសាធារណៈជនក៏អាចធ្វើទំនាក់ទំនង និងទទួលព័ត៌មានតាមរយៈប្រភពទាំងនេះបានដូចគ្នាដែរ។

- គេហទំព័រ : www.nssf.gov.kh
- Facebook Page : បេឡាជាតិរបបសន្តិសុខសង្គម-ប.ស.ស
- សារអេឡិចត្រូនិច : info@nssf.gov.kh
- លេខទូរសព្ទ័ព័ត៌មានបន្ទាន់ (Hotline) ៖ ១២៨៦

គេហទំព័រ និង Facebook Page របស់ប.ស.ស មានបញ្ចូលនូវព័ត៌មាននិងឯកសារសំខាន់ជាច្រើនដូចជា ៖

១. លិខិតបទដ្ឋានគតិយុត្តរបស់ប.ស.ស ទាំងអស់

២. មន្ទីរពេទ្យដែលប.ស.ស ចុះកិច្ចព្រមព្រៀងទាំង២៥ រាជធានី/ខេត្ត

៣. លេខទូរសព្ទភ្នាក់ងារ ប.ស.សសម្រាប់មន្ទីរពេទ្យធំៗ

៤. លេខទូរសព្ទរបស់មន្ទីរពេទ្យ និងរថយន្តសង្គ្រោះបន្ទាន់

៥. ព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារប.ស.ស

បច្ចុប្បន្នលេខទូរសព្ទព័ត៌មានបន្ទាន់(Hotline) ១២៨៦ បានដាក់ឱ្យដំណើរការ២៤ម៉ោងពេញមួយថ្ងៃ ដែលបម្រើការ៧ថ្ងៃ ក្នុង១សប្តាហ៍ ។

**ឃ/ ភ្នាក់ងារប.ស.ស ប្រចាំតាមបណ្តាមូលដ្ឋានសុខាភិបាល**

ភ្នាក់ងាររបស់ប.ស.ស ប្រចាំមូលដ្ឋានសុខាភិបាលនីមួយៗមានភារកិច្ច៖

- ជួយសម្រួលការងាររដ្ឋបាលផ្សេងៗ រវាងមូលដ្ឋានសុខាភិបាល និងសមាជិកប.ស.ស ដែលទៅទទួលសេវាសុខាភិបាលបាននៅតាមបណ្តាលមូលដ្ឋានសុខាភិបាលនីមួយៗ
- ជាភ្នាក់ងារសម្រាប់ផ្តល់ព័ត៌មានដល់បណ្តាលសមាជិកប.ស.ស ដែលមកទទួលសេវាសុខាភិបាលនៅតាមបណ្តាមូលដ្ឋានសុខាភិបាលនីមួយៗ
- ជួយអន្តរគមន៍ផ្ទាល់ជាមួយគ្រូពេទ្យ បុគ្គលិកពេទ្យ ឬមូលដ្ឋានសុខាភិបាលដែលខ្លួននៅប្រចាំការ
- ចូលរួមប្រជុំផ្ទៃក្នុង ជាមួយមូលដ្ឋានសុខាភិបាលដែលខ្លួនប្រចាំការជារៀងរាល់ខែ និងមានភារកិច្ចក្នុងការពាំនាំនូវមតិយោបល់រិះគន់របស់សមាជិកពាក់ព័ន្ធនឹងការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលខ្លួនប្រចាំការ។ កិច្ចប្រជុំផ្ទៃក្នុងនេះជាទូទៅដឹកនាំដោយប្រធានមូលដ្ឋានសុខាភិបាលផ្ទាល់
- ជាអ្នកពាំនាំនូវមតិយោបល់រិះគន់របស់សមាជិកប.ស.ស និងពាក់ពន្ធ័នឹងសេវាប.ស.ស និងបញ្ហាប្រឈមនានាដែលមិនត្រូវបានដោះស្រាយនូវមូលដ្ឋានសុខាភិបាលនីមួយៗ មកជូនថ្នាក់ដឹកនាំជំនាញរបស់ប.ស.សដើម្បីរកដំណោះស្រាយ ឬដាក់ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលប.ស.ស ដើម្បីពិភាក្សារកដំណោះស្រាយ ។

### ង/ គណៈកម្មការវេជ្ជសាស្ត្រ[៥៧]

គណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម គឺជាគណៈកម្មការអន្តរក្រសួង ក្នុងនោះរួមមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល។ គណៈកម្មការនេះ មានតួនាទីភារកិច្ចផ្តល់យោបល់ចំពោះការកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងាររបស់កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ និងផ្តល់យោបល់លើស្ថានភាពរបស់មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។ ដូច្នេះ គណៈកម្មការវេជ្ជសាស្ត្ររបស់ ប.ស.ស សម្រាប់ផ្នែកថែទាំសុខភាពពុំមាននៅឡើយទេ។ ប៉ុន្តែ គណៈកម្មការវេជ្ជសាស្ត្ររបស់ប.ស.ស ផ្នែកថែទាំសុខភាពនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗខាងមុខ ដើម្បីធានានូវប្រសិទ្ធភាពនៃសេវាថែទាំសុខភាពនិងដើម្បីដោះស្រាយវិវាទ ឬបញ្ហាផ្សេងៗ ពិសេសបញ្ហាពាក់ព័ន្ធនឹងសុខភាព និងតាមបណ្តាមូលដ្ឋានសុខាភិបាលជាដៃគូ ។

## កថាខណ្ឌទី២ បែបបទនៃការបង់ភាគទាន និងតាវកាលិក

### ក/ ការបង់ភាគទាន

និយោជកនិងកម្មករនិយោជិតដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ប.ស.ស។[៥៨] បន្ទាប់ពី បានចុះបញ្ជិកាផ្នែកថែទាំសុខភាពក្នុងបេឡាជាតិរបបសន្តិសុខសង្គម និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកតព្វកិច្ចប្រមូលភាគទាន និងបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់បេឡាជាតិរបបសន្តិសុខសង្គម។[៥៩] រដ្ឋបាលនៃរោងចក្រសហគ្រាស ត្រូវរៀបចំបញ្ជិកាក្នុងប្រព័ន្ធដែលបានរៀបចំដោយប.ស.ស អំពីការកំណត់ប្រាក់ដែលជាប់ភាគទានតាមចំនួនប្រាក់ខែសរុបនៃ កម្មករនីមួយៗ និងប្រាក់ដែលនិយោជកមានបន្ទុកចូលរួមបង់ជាមួយកម្មករនិយោជិតរួចយកចំនួនទឹកប្រាក់សរុបនៃប្រាក់ជាប់ភាគទាន របស់កម្មករនិយោជិតទៅកាន់ធនាគារអេស៊ីលីដា(Acleda Bank) ភ្ជាប់ជាមួយលេខអត្តសញ្ញាណសហគ្រាស និងចំនួនទឹកប្រាក់សរុប

[៥៧] ប្រកាសលេខ០៨៨/០៩ កប/ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម

[៥៨] ប្រការ៤ វាក្យខណ្ឌ១ នៃប្រកាសរួមលេខ២២០ ក.ប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

[៥៩] ប្រការ៤ វាក្យខណ្ឌ២ នៃប្រកាសរួមលេខ២២០ ក.ប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

ដែលត្រូវបង់។ រដ្ឋបាលត្រូវភ្ជាប់មកជាមួយនូវបណ្ណ័ដាក់ប្រាក់អេស៊ីលីដា លិខិតប្រកាសបង់ភាគទានហានិភ័យការងារ និងថែទាំសុខភាព លិខិតបញ្ជាក់ព័ត៌មាន សហគ្រាស(Form B) និង Flash ព័ត៌មានកម្មករនិយោជិតមកកាន់ការិយាល័យបញ្ជិកានិងភាគទាន ដើម្បីបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ប.ស.ស។ ការបង់វិភាគទានទៅធនាគារអេស៊ីលីដា ត្រូវធ្វើឡើងសម្រាប់ខែនីមួយៗនៅមុនថ្ងៃទី១៥ នៃខែបន្ទាប់។[៦០]

### ខ/ អត្រាភាគទាន

ការបង់ភាគទានជាកតព្វកិច្ចដែលនិយោជកត្រូវបង់មានអត្រា១.៣% ហើយកម្មករនិយោជិតត្រូវបង់ក្នុងអត្រា១.៣%នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំខែរបស់កម្មករនិយោជិត។[៦១] តារាងភាគទានផ្នែកថែទាំសុខភាពនៃប្រកាសលេខ ២២០ ក.ប/ប្រកស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព[៦២] ហើយអត្រាប្តូរប្រាក់មធ្យមប្រចាំខែត្រូវកំណត់តាមសេចក្តីជូនដំណឹងរបស់ប.ស.ស ដោយយោងតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិ ។

### គ/ ការផ្តល់សេវាថែទាំសុខភាព

ដើម្បីទទួលបានសេវាសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រដោយឥតគិតថ្លៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌ[៦៣] ជាសមាជិកដែលកំពុងបំពេញការងារក្នុង សហគ្រាស គ្រឹះស្ថានដែលចុះបញ្ជិកាក្នុងប.ស.ស សម្រាប់របបថែទាំសុខភាព, បានចុះបញ្ជិកានៅក្នុងប.ស.ស, និងបានបង់ភាគទានសម្រាប់ថែទាំសុខភាពក្នុងរយះពេល២ខែជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច៦ខែក្នុងកំឡុងពេល១២ខែចុងក្រោយគិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព ។

ក្នុងករណី សមាជិកបានបង់ភាគទាន២ខែជាប់គ្នាហើយ ប៉ុន្តែដោយសារការបញ្ចប់កិច្ចសន្យាការងារសមាជិកប.ស.ស មានសិទ្ធទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយះពេល២ខែទៀតគិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងាររបស់សមីជន។

---

[៦០] ប្រការ៥ វាក្យខណ្ឌ១ នៃប្រកាសរួមលេខ២២០ ក.ប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

[៦១] ប្រការ៣ នៃប្រកាសរួមលេខ២២០ ក.ប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

[៦២] សូមមើលឧបសម្ព័ននៃសារណានេះ

[៦៣] ប្រការ៦ ចំណុច១ នៃប្រកាសលេខ១០៩ កប/ប្រក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

នៅពេលកម្មករនិយោជិតជាសមាជិកប.ស.ស ទៅទទួលសេវាថែទាំសុខភាព ត្រូវភ្ជាប់មកជាមួយនូវបណ្ណ័សមាជិកភាពប.ស.ស ឬអត្តសញ្ញាណសមាជិកប.ស.ស និងបានទៅប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមជាមួយប.ស.ស (មូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ដោយប.ស.ស មានរូបសម្គាល់សញ្ញាប.ស.ស) ។

បើលេខអត្តសញ្ញាណសមាជិកប.ស.ស មានសុពលភាព អ្នកជំងឺអាចទទួលបាននូវសេវាថែទាំវេជ្ជសាស្ត្រនៃសេវាថែទាំសុខភាព (លើកលែងជំងឺ១៤មុខនិងសេវាមិនរាប់បញ្ចូលក្នុងសេវាថែទាំវេជ្ជសាស្ត្រ) និងសេវាបង្ការ សេវាសង្គ្រោះបន្ទាន់ នៅមូលដ្ឋានសុខាភិបាលនិងគ្លីនិកឯកជនដោយទូទាត់មកវិញពីប.ស.សនូវប្រាក់បំណាច់ប្រចាំថ្ងៃ សេវាបញ្ជូនជនរងគ្រោះ មិនអាចព្យាបាលជា ឬបញ្ជូនសពនិងប្រាក់បំណាច់ សម្រាប់លំហែមាតុភាព ។

បើលេខអត្តសញ្ញាណសមាជិកប.ស.សគ្មានសុពលភាព អ្នកជំងឺមិនអាចទទួលបានសេវាថែទាំវេជ្ជសាស្ត្រនៃសេវាថែទាំសុខភាពបានទេ។ មូលដ្ឋានសុខាភិបាលត្រូវរៀបចំថ្លៃទូទាត់សេវាថែទាំវេជ្ជសាស្ត្រមកប.ស.ស ហើយមន្ត្រីដែលមានជំនាញសុខាភិបាលមានភារកិច្ចពិនិត្យថ្លៃទូទាត់សេវាថែទាំវេជ្ជសាស្ត្រ ។

ចំពោះការព្យាបាលសម្រាប់១៤ករណីខាងក្រោម មិនត្រូវបានរាប់បញ្ចូលក្នុងការព្យាបាលថែទាំវេជ្ជសាស្ត្រដោយឥតគិតថ្លៃនោះទេ លើកលែងករណីសង្គ្រោះបន្ទាន់ប.ស.សផ្តល់ជូននូវសេវាទាំងនេះ។ សេវាទាំង១៤ មុខរួមមាន ៖[៦៤]

១. ការព្យាបាលដោយឥតគិតថ្លៃដែលមានចែងក្នុង គោលនយោបាយសុខាភិបាលសាធារណៈ
២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣. ការព្យាបាល និងការវះកាត់ប្តូរភេទ
៤. ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ (ខួរឆ្អឹង តំរងនោម ថ្លើម បេះដូង និងលំពែង...)
៥. សេវាបង្កកំណើតដោយសិប្បនិម្មិត
៦. ការព្យាបាលដោយខ្លួនឯង
៧. ការព្យាបាល ឬ វះកាត់ដើម្បីជាប្រយោជន៍ នៃការកែលំអផ្នែកណាមួយនៃរាង្គកាយ
៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និង ការព្យាបាលដោយកាំរស្មីឡាស៊ែ

[៦៤] ប្រការ៤ នៃប្រកាសលេខ១០៩ ក.ប/ប្រក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៩. ការព្យាបាលញៀនសុរា និង ផ្តាច់គ្រឿងញៀន

១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត

១១.ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២. ការវះកាត់បេះដូង និង សរសៃឈាមបេះដូង

១៣. ការលាងឈាម

១៤. ការព្យាបាលមហារីកដោយសាធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចបានរៀបរាប់ខាងលើត្រូវបានផ្តល់ជូន ។

ការព្យាបាលជំងឺរាំរ៉ៃ ត្រូវធ្វើឡើងក្នុងមូលដ្ឋានសុខាភិបាលសាធារណៈតែប៉ុណ្ណោះ។ ក្នុងការព្យាបាលជំងឺនេះ ប.ស.ស ទទួលខុសត្រូវតែចំពោះការផ្តល់សេវាពិគ្រោះជំងឺក្រៅ និងសម្រាកពេទ្យ ដោយប្រើប្រាស់ **ឱសថសារវន្ត**[៦៥] ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីឱសថសារវន្តជាបន្ទុករបស់សមាជិក ប.ស.សផ្ទាល់។ ជំងឺរ៉ាំរ៉ៃទាំងនេះមានចំនួន ១៤ មុខរួមមាន ៖[៦៦]

១. ជំងឺខ្សោយបេះដូង (Cardiac Failure)

២. ជំងឺសាច់ដុំបេះដូង (Cardiomyopathy)

៣. ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)

៤. ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)

៥. ជំងឺតម្រង់នោមរ៉ាំរ៉ៃ (Chronic renal disease)

៦. ជំងឺក្រិនថ្លើម (Cirrhosis of the liver)

៧. ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)

៨. ជំងឺទឹកនោមផ្អែមប្រភេទទី១ និង ទី២ (Diabetes Mellitus Type 1&2)

៩. ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)

១០. ជំងឺក្រិនសេរីរាង្គ (Multiple Sclerosis)

១១. ជំងឺវិកលចរិត (Schizophrenia)

១២. ជំងឺលុយពុស (Systemic Lupus Erythematous)

---

[៦៥] ឱសថសារវន្ត គឺជាឱសថដែលប.ស.ស ផ្តល់ទៅមូលដ្ឋានសុខាភិបាលសាធារណៈទុកសម្រាប់ព្យាបាលជំងឺរាំរ៉ៃ

[៦៦] ប្រការ២ នៃប្រកាសលេខ២៣៨ ក.ប/ប្រក ស្តីការកំណត់ជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១៣. ជំងឺលើសឈាម (Hypertension)

១៤. ជំងឺតាឡាសសីមី (Thalassemia)

ប.ស.សទទួលបន្ទុកផ្តល់ និងកំណត់យន្តការទូទាត់ថ្លៃសេវាបង្ការសុខភាពដែលការប្រើប្រាស់សេវានេះ ត្រូវធ្វើឡើងនៅមូលដ្ឋានសុខាភិបាលសាធារណៈចំពោះការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីពិសោធន៍ឯកជនក្នុងនិងក្រៅប្រទេសប.ស.ស មិនទូទាត់ថ្លៃសេវានេះឡើយលុះត្រាតែមានការអនុញ្ញាតិជាមុនពី ប.ស.ស។ សេវាបង្ការសុខភាពមានចំនួន៦មុខរួមមាន៖[៦៧]

១.សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត (Rabies Vaccination)

២. សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត (Antirabic Serum)

៣. សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស (Anti-Tetanus Serum)

៤. សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ (Antivenom Immunoglubulin)

៥. សេវាពិនិត្យឈាមរកជំងឺពកក៖ TSH (Thyroid-Stimulating Hormone) និង Free T3 (Free Triiodothronine) , Free T4 (Free Thyroxine)

៦. សេវាពិនិត្យឈាម កំណត់អរបោធាតុមហារីក (Cancer Humeraux Marqueurs) ក្រោយការព្យាបាលជំងឺមហារីកដោះវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និង/ក្រោយ ការព្យាបាលជំងឺមហារីកបាញ់កាំរស្មីអ៊ិច ៖ មាន CA15-3 (Cancer Antigen15-3), CA19-9 (Cancer Antigen19-9), CA125 (CancerAntigen125), PSA (Prostate-Specific-Antigen) , HCG (Beta-Human Chorionic Gonadotropin).

### ឃ/ តារកាលិកថៃទាំសុខភាព

តារការលិកថៃទាំសុខភាពរួមមានការផ្តល់កញ្ចប់តារកាលិកសុខភាព និងសេវាបង្ការសុខភាពដែលបានកំណត់ដូចខាងក្រោម ៖[៦៨]

[៦៧] ប្រការ២ នៃប្រកាសលេខ០៤៩/១៧ កប/ប្រក ប.ស.ស ស្តីពីការដាក់បញ្ចូលសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថៃទាំសុខភាព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

[៦៨] ប្រការ៣ នៃប្រកាសលេខ១០៩ ក.ប/ប្រក ស្តីពីតារកាលិកថៃទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១/ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ៖ ការពិគ្រោះជំងឺក្រៅ, ការសម្រាកពេទ្យ, សង្គ្រោះបន្ទាន់, ព្យាបាលដោយស្នំ និងដោយចលនា, សម្រាលកូន និងព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន, និងសេវាស្តារនីតិសម្បទា(ស្តារលទ្ធភាពពលកម្ម)។

២/ ប្រាក់ឈ្នួល ឬ ប្រាក់បំណាច់ប្រចាំថ្ងៃ ៖

- កម្មករនិយោជិតដែលមានជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុបណ្តាលឱ្យអាក់ខានការងារចាប់ពី៨ថ្ងៃឡើង និងមានវេជ្ជបញ្ជាប.ស.ស ត្រូវទទួលបន្ទុកផ្តល់នូវប្រាក់ឈ្នួល ឬប្រាក់បំណាច់ប្រចាំថ្ងៃជូនកម្មករ និយោជិតដោយគិតចាប់ពីថ្ងៃដំបូងទៅ។ ប៉ុន្តែបើការអាក់ខានការងារដោយមូលហេតុនេះមានរយៈពេល ក្រោម៨ថ្ងៃ ប្រាក់ឈ្នួលជាបន្ទុករបស់និយោជក
- រីឯក្នុងករណីដែលកម្មករនិយោជិតដែលបានបង់ភាគទានយ៉ាងតិច៩ខែជាប់គ្នាការសម្រាកមាតុភាព(ដោយភ្ជាប់មកជាមួយនូវសេចក្តីចំលងសំបុត្រកំណើត)ប.ស.សផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃចំនួន៩០ ថ្ងៃ គិតក្នុងអត្រា៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់កម្មករនិយោជិត។ ចំពោះសមាជិកប.ស.សដែលបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលមិនបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស ទោះករណីសង្គ្រោះបន្ទាន់ក្តី មិនសង្គ្រោះបន្ទាន់ក្តីហើយបានបំពេញកតព្វកិច្ចបង់វិភាគទានយ៉ាងតិច៩ខែជាប់គ្នា អាចទាមទារនូវប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាពពីប.ស.សបាន លុះត្រាតែសមីជនមកពិនិត្យតាមដានស្ថានភាពក្រោយសម្រាលនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស។[៦៩]

៣/ សេវាបញ្ជូន អ្នកជំងឺឬជនរងគ្រោះ៖ ផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដោយរថយន្តគិលានសង្គ្រោះរបស់ មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀត ។

៤/ ការបញ្ជូនសព ឬអ្នកជំងឺដែលមិនអាចព្យាបាលជា។ ផ្តល់ជូនតាមតម្លៃមូលដ្ឋានសុខាភិបាលដោយពុំគិតពីប្រភេទមធ្យោបាយនៃការដឹកជញ្ជូន ហើយទទួលស្គាល់ដោយប.ស.ស ។

៥/ សេវាបង្ការសុខភាព៖ ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅបញ្ហាសុខភាពដទៃទៀត ។

➢ ការទូទាត់លើការព្យាបាល និងសេវាថែទាំសុខភាពដោយការដាក់ឯកសារស្នើសុំទាមទារតាវកាលិក ថែទាំសុខភាព ដោយប្រើប្រាស់សេវា និងបង់ប្រាក់ជាមុនរួមមាន ៖

- សេវាសង្គ្រោះបន្ទាន់៖ ព្យាបាលនៅគ្រប់មន្ទីពេទ្យកិច្ចសន្យា និងមិនមែនកិច្ចសន្យា

[៦៩] សេចក្តីណែនាំស្តីពីសិទ្ធទទួលបានប្រាក់សម្រាលមាតុភាពចំពោះសមាជិកប.ស.សដែលបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលមិនបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

- រថយន្តដឹកសព ឬអ្នកជំងឺមិនមានសង្ឃឹមជា
- ប្រាក់បំណាច់ប្រចាំថ្ងៃដែលទទួលការសម្រាកព្យាបាលលើសពី៧ថ្ងៃ
- ប្រាក់លំហែមាតុភាព

ដើម្បីទទួលបានតាវកាលិកសេវាខាងលើនេះ កម្មករនិយោជិត ឬអ្នកតំណាងត្រូវបំពេញបែបបទរដ្ឋបាលរួចយកមកដាក់នៅការិយាល័យតាវកាលិកដើម្បីស្នើសុំធ្វើការទូទាត់។ នៅពេលដែលបានទទួលបានការសម្រេចទូទាត់ជាផ្លូវការ កម្មករនិយោជិត ឬអ្នកតំណាងនឹងទទួលបាន នូវសេចក្តីសម្រេចផ្តល់តាវកាលិកថែទាំសុខភាព ពីបេឡាជាតិរបបសន្តិសុខសង្គមដើម្បីយកទៅបើកជាសាច់ប្រាក់នៅធានាគារអេស៊ីលីដានៅគ្រប់សាខារាជធានី/ខេត្ត ។

### ង/ ការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

ការទូទាត់ថ្លៃសេវាមូលដ្ឋានសុខាភិបាល អាចធ្វើទៅបានលុះត្រាតែមានការកំណត់ពីលទ្ធភាពផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្រិតនៃការទូទាត់ថ្លៃតាមប្រភេទករណី និងកម្រិតនៃការទូទាត់ថ្លៃតាមប្រភេទសេវាដោយប.ស.ស។ ទោះជាយ៉ាងណាក៏ដោយ ការកំណត់ពីកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលនេះ មិនត្រូវទាបជាងកម្រិតកំណត់ដោយក្រសួង សុខាភិបាលឡើយ។ ការទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាលត្រូវអនុវត្តតាមយន្តការទូទាត់ថ្លៃសេវាដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣កប/ប្រកចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព។ ប.ស.សត្រូវទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងតាមរយៈប្រព័ន្ធធនាគារ ។

ប.ស.ស អាចបដិសេធថ្លៃសេវាទាំងស្រុង ឬមួយផ្នែកនៃសេវាដែលស្នើដោយមូលដ្ឋានសុខាភិបាលក្នុងករណីដូចខាងក្រោម៖

- សេវាសុខាភិបាលដែលផ្តល់ឱ្យលើសពីតម្រូវការចាំបាច់នៃបញ្ហាសុខភាព ឬលក្ខខណ្ឌជំងឺ
- អន្តរគមន៍ ឬបែបបទនៃការធ្វើរោគវិនិច្ឆ័យការផ្តល់ការព្យាបាល និងថែទាំមិនស្របតាមវិធីសាស្ត្រនៃការព្យាបាល ឬគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- ប្រើប្រាស់ឱសថមានគុណភាពអន់ ឬគ្មានប្រភពច្បាស់លាស់ ឬគ្មានអាជ្ញាបណ្ណ័ទទួលស្គាល់ដោយក្រសួងសុខាភិបាល និងការចេញវេជ្ជបញ្ជាមិនត្រឹមត្រូវ

- ក្លែងបន្លំឯកសារ ឬផ្តល់ព័ត៌មានមិនពិតដែលជាយន្តការសម្រាប់ទូទាត់ថ្លៃសេវា
- ការទទួលយកនូវការអនុវត្តតាមបទដ្ឋាន និងការព្យាបាលដែលមានគម្លាតខុសគ្នាទាំងស្រុង។

### ច/វិធីសាស្ត្រទូទាត់សេវាព្យាបាលផ្នែកថែទាំសុខភាព

#### ច.១ ជាមួយមូលដ្ឋានសុខាភិបាល

ការទូទាត់សេវាព្យាបាលថែទាំផ្នែកថែទាំសុខភាព គឺជាវិធីសាស្ត្រនៃការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសពសម្រាប់ផ្នែកថែទាំសុខភាពដែលប.ស.ស ត្រូវផ្តល់ជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ឬមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។ ប.ស.ស ធ្វើការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រតាមវិធីសាស្ត្រពីរយ៉ាង៖[៧០] វិធីសាស្ត្រទូទាត់ថ្លៃតាមករណី និងវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា ។

- **វិធីសាស្ត្រទូទាត់ថ្លៃតាមករណី ៖**[៧១] ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមតម្លៃថេរតាមប្រភេទករណីជំងឺ និង តាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ។
- **វិធីសាស្ត្រទូទាត់ថ្លៃសេវាតាមប្រភេទសេវា ៖**[៧២]ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេស។

#### ច.២ សុពលភាពនៃការទទួលបានសេវាថែទាំសុខភាព

បន្ទាប់ពីបានបង់ភាគទាន០២ខែជាប់គ្នាហើយនៅខែបន្ទាប់ទៀត បើកម្មករនិយោជិតគ្មានសមត្ថភាពបំពេញកតព្វកិច្ចបង់ភាគទានបន្តទៀត ដោយសារការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតមានសិទ្ធទទួលសេវាក្នុងកំឡុងពេល០២ខែបន្ទាប់ទៀត គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងាររបស់សមីជន។[៧៣] រីឯកម្មករនិយោជិតដែលបាន បង់ភាគទានចំនួន០៦ខែ ក្នុងកំឡុង

---

[៧០] ប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦

[៧១] សូមមើលឧបសម្ព័ន្ធ១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

[៧២] សូមមើលឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

[៧៣] ចំណុច៦.១ នៃប្រការ៦ នៃប្រកាស១០៩ កប/ប្រក ស្តីពីតារកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ពេល១២ខែចុងក្រោយគិតរហូតដល់ពេលមានបញ្ហាសុខភាព ឬមាតុភាព អាចទទួលបាននូវសេវាថែទាំសុខភាពរយៈពេល០៦ខែបន្ទាប់។ប៉ុន្តែក្នុងករណីកម្មករនិយោជិត សម្រាកព្យាបាលនៅមន្ទីរពេទ្យទោះស្ថិតនៅក្នុងស្ថានភាពណាមួយនៃស្ថានភាពខាងលើក៏ដោយ ក៏ពួកគាត់មានសិទ្ធទទួលបាននូវសេវាវេជ្ជសាស្ត្ររហូតដល់១៨០ថ្ងៃ។ អ្នកជំងឺ ឬជនរងគ្រោះ អាចចូលទៅប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាលដែលមានសញ្ញារបស់ ប.ស.ស ឬមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតក្នុងករណីសង្គ្រោះបន្ទាប់។ ប.ស.ស ធ្វើការទូទាត់សងមកវិញទៅតាមវិធីសាស្ត្របង់ថ្លៃតាមករណី និងបង់ថ្លៃតាមសេវា លុះត្រាតែ ជនរងគ្រោះ ឬសិទ្ធវន្តជូនដំណឹងមក ប.ស.ស ក្នុងកំឡុងពេល៤៥ម៉ោងតាមរយៈលេខទូរសព្ទបន្ទាន់ ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "សង្គម និងរដ្ឋ ៖ របបសន្តិសុខសង្គម នៅព្រះរាជាណាចក្រកម្ពុជា (ប.ស.ស)" រួចមកខ្ញុំបាទបានពិនិត្យឃើញថា បេឡាជាតិរបបសន្តិសុខសង្គម បានដាក់ឱ្យដំណើរការ របបហានិភ័យការងារនៅខែវិច្ឆិកា ឆ្នាំ២០០៨ បានជួយសម្រួលការលំបាកជាច្រើនដល់កម្មករនិយោជិតដែលបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាជាមួយប.ស.ស។ លើសពីនេះកម្មករនិយោជិតដែលទទួលរងហានិភ័យការងារ ក្នុងពេលបំពេញការងារ ក្នុងពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ នឹងបានទទួលការថែទាំ និងព្យាបាលជំងឺ ក្នុងពេលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាល។ ម្យ៉ាងវិញទៀតកម្មករនិយោជិត ក៏នឹងទទួលបានតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារ ហើយ ករណីស្លាប់សិទ្ធវន្តនៃជនរងគ្រោះដែលរងហានិភ័យការងារក៏នឹងទទួលបានតាវកាលិកពីបស.ស.ស ផងដែរ ។

ទន្ទឹមនឹងនេះដែរ ប.ស.ស បានដាក់ឱ្យដំណើរការរបបថែទាំសុខភាពនាពេលថ្មីនេះ ដែលជារបត់ថ្មីមួយទៀត ក្នុងការផ្តល់នូវសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់កម្មករនិយោជិត។ ការផ្តល់របបថែទាំសុខភាពតាមរយៈ ប.ស.ស បានផ្តល់នូវការយកចិត្តទុកដាក់ ដើម្បីឱ្យកម្មកនិយោជិត ទទួលបាននូវការពិនិត្យ និងព្យាបាលសុខភាព កាត់បន្ថយលើការចំនាយផ្នែកសុខភាព នៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗទៀត។ នាពេលខាងមុខ ប.ស.ស នឹងដាក់ឱ្យអនុវត្តនូវរបបសម្រាប់មន្ត្រីរាជការសាធារណៈ ដែលនឹងទទួលបាននូវរបបហានិភ័យការងារ និងសេវាថែទាំសុខភាពដូចកម្មករនិយោជិត។ បន្ថែមពីនេះ ប.ស.ស មានទិសដៅដាក់ឱ្យអនុវត្តនូវរបបប្រាក់សោធននិវត្ត សម្រាប់កម្មករនិយោជិតដែលរបបនេះចាត់ទុកជាការគាំពាររយៈពេលវែងពោលគឺការគាំពាររហូតដល់ដំណាក់កាលនៃជីវិតចុងក្រោយរបស់កម្មករនិយោជិត។

សរុបសេចក្តីមក ការផ្តល់សេវាសាធារណៈរួមមាន របបហានិភ័យការងារ របបថែទាំសុខភាពតាមរយៈ ប.ស.ស គន្លងមក បានផ្តល់នូវប្រសិទ្ធភាព និងគណនេយ្យភាព ជាច្រើនជូនដល់កម្មករនិយោជិត។ ជាចុងក្រោយសូមគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងអាណាព្យាបាលទាំងពីរ រួមមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ខិតខំបន្តកិច្ចគាំពារនេះ និងសម្រេចបានចំពោះរបបផ្នែកសោធន ជាបន្តទៀតប្រកបដោយនិរន្តរភាព ។

## ឯកសារយោង

### ច្បាប់

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
2. ច្បាប់ស្តីពីការងារ លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ១៩៩៧
3. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២

### អនុក្រឹត្យ

4. អនុក្រឹតលេខ១៦ អនក្របក ចុះថ្ងៃទី២ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
5. អនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ប្រកាស

6. ប្រកាសលេខ ០២២/០៨ កប.ប្រក ចុះថ្ងៃទី១១ ខែកម្ភះ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ
7. ប្រកាសលេខ០២១/០៨កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភ: ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និង កម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
8. ប្រកាសលេខ ២៨៥ កប/ប្រក ស្តីពីការកែសម្រួលប្រកាសលេខ៣,៤,៥នៃប្រកាសលេខ០២១/០៨កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភ: ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
9. ប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ
10. ប្រកាសលេខ២៩៤ កប/ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និង ប្រការ៥ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ
11. ប្រកាសលេខ១១០ កប/ប្រក ស្តីពីការជូនដំណឹងហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
12. ប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាកាលិកហានិភ័យការងារ

13. ប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៧ និង ប្រការ៨ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពី តារកាលិកហានិភ័យការងារ
14. ប្រកាសលេខ២៣៣ កប/ប្រក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និង ប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ថ្នាំ២០០៨ ស្តីពី តារកាលិកហានិភ័យការងារ
15. ប្រកាសលេខ១៧៧ កប/ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីសមាសភាព និង ការ ប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស
16. ប្រកាសលេខ០៩៣/១៦ ស្តីពីការកំណត់ដំណាក់កាល និង កាលបរិច្ឆេទនៃការអនុវត្តរបប សន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះ
បណ្តាលវិជ្ជាជីវៈ
17. ប្រកាសអន្តរក្រសួងលេខ២៩១ កប/ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រម ព្រៀងការប្រើប្រាស់និង ការផ្តល់សេវាសុខភាព រវាងបេឡាជាតិរបបសន្តិសុខសង្គម និង មូលដ្ឋាន
សុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសុខាភិបាល ។
18. ប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការ ទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
19. ប្រកាសលេខ០៨៨/០៩ កប/ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈ កម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម
20. ប្រកាសរួមលេខ២២០ ក.ប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគ ទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦
21. ប្រកាសលេខ២៣៨ ក.ប/ប្រក ស្តីការកំណត់ជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំ សុខភាព ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
22. ប្រកាសលេខ០៤៩/១៧ កប/ប្រក ប.ស.ស ស្តីពីការដាក់បញ្ចូលសេវាបង្ការសុខភាពនៅក្នុង របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
23. ប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព ចុះ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦

## សេចក្តីជូនដំណឹង

24. សេចក្តីជូនដំណឹងស្តីពីនីតិវិធីនៃការបង់ភាគទាន និង ការដោះស្រាយហានិភ័យការងារ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០៨

## សេចក្តីណែនាំ

25. សេចក្តីណែនាំលេខ ៦៩/១៥ ប.ស.ស ស្តីពីនីតិវិធី និង បែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥
26. សេចក្តីណែនាំស្តីពីសិទ្ធទទួលបានប្រាក់សម្រាលមាតុភាពចំពោះសមាជិកប.ស.សដែលបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលមិនបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

## របាយការណ៍

27. ផែនការយុទ្ធសាស្ត្រអនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៣-២០១៥ របស់ ប.ស.ស
28. របាយការណ៍ ប.ស.ស ស្តីពីយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៤-២០១៨

## គេហទំព័រ

29. https://www.ssa.gov/history/age65.html
30. https://en.wikipedia.org/wiki/Social_Security_(United_States)
31. http://www.nssf.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

# Sub-Decree

## On

## The establishment of National Social Security Fund

# មាតិកា

**ជំពូកទី ១** បទប្បញ្ញត្តិទូទៅ............................................................... ០២

**ជំពូកទី ២** រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម............................. ០៣

២.១ ផ្នែកទី ១ ក្រុមប្រឹក្សាភិបាល ................................................. ០៣

២.២ ផ្នែកទី ២ អង្គការប្រតិបត្តិនៃ ប.ស.ស.................................... ០៨

**ជំពូកទី ៣** ការគ្រប់គ្រងហិរញ្ញវត្ថុ ....................................................... ១១

៣.១ ផ្នែកទី ១ កិច្ចការគណនេយ្យ ................................................ ១១

៣.២ ផ្នែកទី ២ ប្រភពធនធាន ...................................................... ១២

៣.៣ ផ្នែកទី ៣ ការចំណាយ ........................................................ ១៣

៣.៤ ផ្នែកទី ៤ ប្រាក់ត្រៀមបម្រុង ................................................. ១៤

៣.៥ ផ្នែកទី ៥ មូលនិធិបង្វិល ...................................................... ១៤

៣.៦ ផ្នែកទី ៦ ការវិភាគសន្តិសុខសង្គម ........................................ ១៥

**ជំពូកទី ៤** ភាគទាន និងតាវកាលិកសន្តិសុខសង្គម ............................ ១៥

៤.១ ផ្នែកទី ១ ភាគទាន ............................................................... ១៥

៤.២ ផ្នែកទី ២ តាវកាលិក ............................................................ ១៦

**ជំពូកទី ៥** អាណាព្យាបាល ..................................................................... ១៦

៥.១ ផ្នែកទី ១ អាណាព្យាបាលបច្ចេកទេស ..................................... ១៦

៥.២ ផ្នែកទី ២ អាណាព្យាលបាលហិរញ្ញវត្ថុ .................................... ១៩

**ជំពូកទី ៦** បទប្បញ្ញត្តិផ្សេងៗ .............................................................. ២១

**ជំពូកទី ៧** អន្តរប្បញ្ញត្តិ ....................................................................... ២៣

**ជំពូកទី ៨** អវសានប្បញ្ញត្តិ .................................................................. ២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមេឡាជាតិរបបសន្តិសុខសង្គម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "**ប.ស.ស**"។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ស.ស** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

**ប.ស.ស** គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

**ប.ស.ស** ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៣.-**

**ប.ស.ស** មានភារកិច្ចដូចខាងក្រោម ÷

១- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

២- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ**ប.ស.ស** ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។

៣- ប្រមូលភាគទានពីសមាជិកនៃ**ប.ស.ស** និងនិយោជក ។

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី ÷

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និង អនាម័យការងារ ។

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ ។

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

## ជំពូកទី ២

## រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**ប.ស.ស**ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ។

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ ( មួយ)រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ ( មួយ)រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១( មួយ)រូប | សមាជិក |
| - តំណាងនិយោជក ២(ពីរ) រូប | សមាជិក |
| - តំណាងកម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ២(ពីរ)រូប | សមាជិក |
| - នាយកនៃ **ប.ស.ស** | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃ **ប.ស.ស**។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ÷

- អនុម័តថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ជាពិសេសសម្រាប់តារាងកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច

- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

**មាត្រា ៦.-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬ នីតិសាស្ត្រ និង មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី)ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះ តំណាងឱ្យ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣(បី)ខែ។ ទោះជាមានកំណត់ដូច្នេះក្តី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ម.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់នាយកនៃ**ម.ស.ស** ឬ សមាជិកដែលមានចំនួន ៥ (ប្រាំ) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ម.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុង សម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ម.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិក ក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិន បើខ្វះកូរ៉ុមការប្រជុំត្រូវលើកទៅ ១៥(ដប់ប្រាំ)ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជា ការបាន លុះណាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

**មាត្រា ៨.-**

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ម.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០(ដប់) ថ្ងៃយ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសំគាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងអស់នោះ ក្នុងកំណត់ហេតុនៃកាប្រជុំចុងក្រោយនេះផង។

**មាត្រា ៩.-**

